# ព្រឹទ្ធសភា

# SENATE MAGAZINE

## ទស្សនាវដ្តីប្រចាំខែឧសភា



លេខ ២៥៩ ឆ្នាំទី២២

ពុទ្ធសករាជ ២៥៦៦ គ្រិស្តសករាជ ២០២២

Issue 259 Volume 22

Before Christ 2566 Common Era 2022

# មាតិកា



## សកម្មភាពថ្នាក់ដឹកនាំ


- គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រជុំពិនិត្យសម្រេចលើរបៀបវារៈចំនួន២ .......... ១
- ព្រឹទ្ធសភាបោះឆ្នោតជ្រើសរើសសមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមចំនួន១រូប .... ២
- គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រជុំពិនិត្យសម្រេចលើរបៀបវារៈចំនួន៣.......... ៣
- ព្រឹទ្ធសភាបើកសម័យប្រជុំវិសាមញ្ញដើម្បីពិនិត្យហើយឱ្យយោបល់លើ សេចក្តីព្រាងច្បាប់ចំនួន២.......................................................................................................៤
- សម្តេចប្រធានព្រឹទ្ធសភាអញ្ជើញជាអធិបតីភាពក្នុងពីធីបុណ្យវិសាខបូជា ..................................៦
- សម្តេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យសមាជិកការិយាល័យនយោបាយបក្សកុម្មុយនីស្តវៀតណាម និង ជាលេខាគណៈកម្មាធិការបក្សរដ្ឋធានីហាណូយចូលជួបសម្តែងការគួរសម........................................ ៧
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកអគ្គរដ្ឋទូតតែងតាំងថ្មីនៃសាធារណរដ្ឋក្រូអាស៊ី ...............................១០
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបគណៈប្រតិភូក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា.................................១១
- ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន សំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង នៅខេត្តកណ្តាល............ ១៤
- ថ្នាក់ដឹកនាំព្រឹទ្ធសភាសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ....................................................១៦




## សកម្មភាពគណៈកម្មការ


- គណៈកម្មការទី១ព្រឹទ្ធសភាសំណេះសំណាលអាជ្ញាធរស្រុក ក្រុមប្រឹក្សាឃុំ នៃស្រុកមណ្ឌលសីមា ខេត្តកោះកុង ..........................................................១៨
- គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភាសំណេះសំណាលអតីតយុទ្ធជន និវត្តជន ចាស់ជរា ជនពិការ និងយុវជន នៅខេត្តក្រចេះ ................................... ២២
- លោកជំទាវ មាន សំអាន សំណេះសំណាលថ្នាក់ដឹកនាំជាស្ត្រីនៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង.......................................................................................................២២
- គណៈកម្មការទី១០ព្រឹទ្ធសភាឈ្វេងយល់ការអនុវត្តច្បាប់ និងការងារតាមវិស័យ ជាសមត្ថកិច្ចនៅខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង.....................................................................២៤
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ សំណេះសំណាលក្រុមប្រឹក្សាឃុំ នៃស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង និងស្រុកកូនមុំ ខេត្តរតនគិរី ....................................................................២៦
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ សំណេះសំណាលក្រុមប្រឹក្សាសង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រធានភូមិ នៅក្រុងក្រចេះ.............................................................................................២៨
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ............................................................ ៣០
- ការងារទទួលពាក្យបណ្តឹង.................................................................................................៣៣
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨.................................... ៤៣
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ .....................................................................៤៨


## សកម្មភាពអគ្គលេខាធិការដ្ឋាន


- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ..............................................៥១



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម អ៊ុំ សារិទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម កែវ ចាន់ណា

ឯកឧត្តម សុខ រិទ្ធី

ឯកឧត្តម ជួន ណា

ឯកឧត្តម គឹម ពិសិដ្ឋ

លោក ជួន សុខធី

លោក ទេព មករា

លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

កញ្ញា សុខ សុជាតា


ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យវិសាខបូជា នៅមុខព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ (ភ្នំឧដុង្គ) ស្រុកពញាឮ ខេត្តកណ្តាល។

ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយជាមួយនឹងគណៈប្រតិភូក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា៕


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ទូរសព្ទ៖** (855 23)211441, 211442, 211443,**ទូរសារ៖** (855 23)211446

E-mail : oumsarith.sgsenate@gmail.com

Website: www.senate.gov.kh

www.elibrary.senate.gov.kh

Facebook: www.facebook.com/senateofcambodia

# គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រជុំពិនិត្យ សម្រេចលើរបៀបវារៈចំនួន២



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

នាព្រឹកថ្ងៃចន្ទ ទី២ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៨:០០នាទី គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានប្រជុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានរបៀបវារៈចំនួន២គឺ៖

**១-ពិនិត្យ និងសម្រេចលើបញ្ជីបេក្ខជនឈរឈ្មោះបោះ-ឆ្នោតជ្រើសតាំងជាសមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមចំនួន១រូប ជំនួសសមាជិកដែលបានទទួលមរណភាព ។**

**២-កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី៨ព្រឹទ្ធសភា នីតិកាលទី៤។**

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានកំណត់យកថ្ងៃអង្គារ ទី៣ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីបន្តសម័យប្រជុំលើកទី៨ ព្រឹទ្ធសភា នីតិកាលទី៤ ដោយមានរបៀបវារៈតែមួយគឺ ការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមចំនួន១រូប ជំនួសសមាជិក ដែលបានទទួលមរណភាព។

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញរាយការណ៍ជូនអង្គប្រជុំ*





*ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាបោះឆ្នោតជ្រើសរើសសមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមចំនួន១រូប




*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ដឹកនាំបន្តសម័យប្រជុំលើកទី៨*

នាព្រឹកថ្ងៃអង្គារ ទី៣ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៨:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី៨ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចំនួន៥៩រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួនមួយ គឺការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមចំនួន១រូប ជំនួសសមាជិក ដែលបានទទួលមរណភាព។

អនុលោមតាមមាត្រា៤ និងមាត្រា៥ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និងយោងលិខិតលេខ៖ ០៣១ ឧកច.របា/២២ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងយុត្តិធម៌ ព្រឹទ្ធសភាត្រូវបានស្នើសុំឱ្យរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន១រូប ជំនួសឯកឧត្តម **អ៊ុំ សារិទ្ធ** សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលបានទទួលមរណភាព។

ព្រឹទ្ធសភាបានបោះឆ្នោតជ្រើសតាំង ឯកឧត្តម **លាង សួត** ជាសមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ដោយមានសំឡេងគាំទ្រចំនួន៥២សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)










*ទិដ្ឋភាពនៃការបន្តសម័យប្រជុំលើកទី៨ ព្រឹទ្ធសភា នីតិកាលទី៤*

# គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាប្រជុំពិនិត្យសម្រេចលើរបៀបវារៈចំនួន៣



សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

នាព្រឹកថ្ងៃអង្គារ ទី១៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៨:០០នាទី គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានរបៀបវារៈចំនួន៣គឺ៖

**១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈនៃព្រឹទ្ធសភា សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មមាត្រា១៤០នៃច្បាប់ស្ដីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤។**

**២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៃព្រឹទ្ធសភា សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី សុវត្ថិភាពម្ហូបអាហារ ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤។**

**៣-កំណត់របៀបវារៈ កាលបរិច្ឆេទ និងសមាសភាពលេខាធិការសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤។**

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃពុធ ទី១៨ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ដោយមានរបៀបវារៈដូចខាងក្រោម៖

**១-ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ។**

**២-ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពីសុវត្ថិភាពម្ហូបអាហារ៕**

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

# ព្រឹទ្ធសភាបើកសម័យប្រជុំវិសាមញ្ញដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន២




*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំសម័យប្រជុំព្រឹទ្ធសភា ជាវិសាមញ្ញ*

នាព្រឹកថ្ងៃពុធ ទី១៨ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៨:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បាន បើកសម័យប្រជុំវិសាមញ្ញ នីតិកាលទី៤ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធាន ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានវត្តមាន សមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៩រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន២ ដូចខាងក្រោម៖

**របៀបវារៈទី១៖ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨។**

សេចក្តីព្រាងច្បាប់នេះ ត្រូវបានឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឡើងរាយការណ៍ជូន



*ឯកឧត្តម សុខ ឥសាន ឡើងអានរបាយការណ៍*

អង្គប្រជុំបានជ្រាបអំពី លទ្ធផលនៃការពិនិត្យ សិក្សាលើ សេចក្តីព្រាងច្បាប់ គឺរៀបចំឡើងក្នុងគោលបំណងកែសម្រួល ចំនួនគណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បី បង្កើនធនធានមនុស្សក្នុងជួរគណៈអភិបាល ដែលជាអង្គ-ប្រតិបត្តិឱ្យមានចំនួនសមស្របតាមស្ថានភាពនៃកំណើន សេដ្ឋកិច្ច កំណើនប្រជាពលរដ្ឋ និងភូមិសាស្ត្រនៃរដ្ឋបាល ថ្នាក់ក្រោមជាតិនីមួយៗ។

សេចក្តីព្រាងច្បាប់នេះតាក់តែងឡើងមាន២មាត្រា ត្រូវ បានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រម ជាលើកដំបូងចំនួន១០៦សំឡេង នៃចំនួនសមាជិករដ្ឋសភា ទាំងមូល កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នាសម័យ ប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦។

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន៣រូប បានឡើងមាន យោបល់ និងលើកជាសំណួរសុំការបំភ្លឺរួចមក ឯកឧត្តម **អ៊ុក ម៉ុង ម៉ណ្ណា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្ម ពិសេស អមដោយថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញ នៃក្រសួងមហាផ្ទៃ បានស្រាយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាព ទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៥សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី២៖ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីសុវត្ថិភាពម្ហូបអាហារ។**

សេចក្តីព្រាងច្បាប់នេះ ត្រូវបានឯកឧត្តម **គង់ សារាជ**



ឯកឧត្តម គង់ សារាជ ឡើងអានរបាយការណ៍

ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា ឡើងរាយការណ៍ជូនអង្គប្រជុំបានជ្រាបអំពី លទ្ធផលនៃការពិនិត្យ សិក្សាលើសេចក្ដីព្រាងច្បាប់ ដែលនឹងបង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យម្ហូបអាហារ ដោយផ្អែកតាមមូលដ្ឋានវិទ្យាសាស្ត្រ និងការវិភាគរកហានិភ័យ ព្រមទាំងកសាងបាននូវចំណុចអាទិភាព និងការត្រួតពិនិត្យបំពេញបន្ថែមឱ្យគ្នាប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តដោយពេញលេញនូវច្បាប់នេះនឹងបង្កើតឱ្យមានរំហូរសេរីនៃទំនិញសេវាកម្ម និងការវិនិយោគ ដើម្បីស្រូបយកអាជីវកម្ម អ្នកជំនាញទេពកោសល្យ និងរំហូរនៃដើមទុនដោយសេរី។

សេចក្ដីព្រាងច្បាប់នេះ ដែលនឹងផ្ដល់សារសំខាន់ក្នុងការកំណត់គោលការណ៍ជាមូលដ្ឋាន ដើម្បីជំរុញឱ្យផលិតផលម្ហូបអាហារមានសុវត្ថិភាព និងអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានជាតិជាធរមាន សំដៅលើកកម្ពស់សុខុមាលភាព និងប្រសិទ្ធភាព នៃការការពារផលប្រយោជន៍អ្នកប្រើប្រាស់ រួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

សេចក្ដីព្រាងច្បាប់នេះតាក់តែងឡើងមាន១១ជំពូក និង ៤៣មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាអនុម័តយល់ព្រមជាលើកដំបូងចំនួន១០២សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូលកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦។

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន៥រូប បានឡើងមានយោបល់ និងលើកជាសំណួរសុំការបំភ្លឺរួចមក ឯកឧត្តម **អង្គ វង្ស វឌ្ឍានា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អមដោយថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញនៃក្រសួងពាណិជ្ជកម្ម បានស្រាយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូល ដោយឥតកែប្រែ ចំនួន៥៩សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



ឯកឧត្តម អង្គ វង្ស វឌ្ឍានា ឡើងការពារសេចក្ដីព្រាងច្បាប់





ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភាលើកដៃអនុម័តច្បាប់

# សម្ដេចប្រធានព្រឹទ្ធសភាអញ្ជើញជាអធិបតីភាពក្នុងពិធីបុណ្យវិសាខបូជា



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ និងលោកជំទាវ អញ្ជើញប្រារព្ធពិធីបុណ្យវិសាខបូជា*

នាថ្ងៃអាទិត្យ ១៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យវិសាខបូជា ដែលជាពិធីបុណ្យមួយដ៏ធំក្នុងព្រះពុទ្ធសាសនាសម្រាប់រម្លឹកដល់ព្រះពុទ្ធសមណគោតម ដែលតែងតែប្រារព្ធជារៀងរាល់ឆ្នាំ នាថ្ងៃពេញបូណ៌មី ថ្ងៃ១៥កើត ខែពិសាខ ដែលជាជំនឿរបស់ពុទ្ធសាសនិក ព្រះសង្ឃ និងគ្រហស្ថជាមហាកុសលដ៏ប្រសើរនោះនៅមុខព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ (ភ្នំឧដុង្គ) ស្រុកពញាឮ ខេត្តកណ្ដាល ដោយមានការយាង និមន្ត និងអញ្ជើញចូលរួមពីសម្ដេចព្រះសង្ឃរាជ សម្ដេចព្រះសង្ឃនាយក សម្ដេចព្រះសង្ឃនាយករង មន្ត្រីសង្ឃ និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ មន្ត្រីរាជការអ្នកមុខអ្នកការ និងពុទ្ធបរិស័ទមកពីទីជិតឆ្ងាយយ៉ាងច្រើនកុះករ។

បន្ទាប់ពីរៀបចំពិធីបុណ្យប្រព្រឹត្តទៅតាមកម្មវិធីប្រពៃណីទំនៀមទម្លាប់ព្រះពុទ្ធសាសនា ដូចជា៖ ការសូត្របទសរភញ្ញថ្វាយព្រះរតនត្រ័យ នមស្ការព្រះរតនត្រ័យ សមាទានសីល ប្រកាសវិសាខបូជាវេរភត្ត ប្រគេន ព្រះសង្ឃ ព្រះសង្ឃភត្តានុមោទនា លោកអាចារ្យឧទ្ទិស ថ្វាយព្រះរាជកុសល សូត្របទរម្លឹកគុណព្រះពុទ្ធបរមគ្រូជាបន្តបន្ទាប់រួចមក សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** និងលោកជំទាវព្រមទាំងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុនសែន** រួមជាមួយនឹងពុទ្ធបរិស័ទជិតឆ្ងាយក៏បានរាប់បាត្រព្រះសង្ឃចំនួន៨០អង្គ ដើម្បីឧទ្ទិសកុសលផលបុណ្យ សូមឱ្យគុណបុណ្យព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាពិសេសសូមឱ្យគុណបុណ្យ ព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ នៃព្រះបរមសារីរិកធាតុតាមឃុំគ្រងជួយបីបាច់ថែរក្សាប្រជាពលរដ្ឋ និងប្រទេសកម្ពុជាទាំងមូលជួបតែសេចក្ដីសុខសប្បាយ និងរីកចម្រើនជារៀងរហូត។

បុណ្យវិសាខបូជា គឺជាពិធីបុណ្យសាសនាដ៏សំខាន់បំផុតក្នុងចំណោមបុណ្យសាសនាដទៃៗទៀត ពីព្រោះពិធីបុណ្យនេះ គឺបានបង្ហាញនូវការគោរពរម្លឹកនឹកដល់ព្រឹត្តិការណ៍ធំៗបី នៃសម័យកាលរបស់ព្រះសម្មាសម្ពុទ្ធ (ព្រះសមណគោតម) គឺថ្ងៃដែលព្រះអង្គទ្រង់បានប្រសូត បានត្រាស់ដឹង និងជាថ្ងៃចូលបរិនិព្វានផងដែរ។ ព្រឹត្តិការណ៍ទាំងបីនេះគឺកើតឡើងចំថ្ងៃ ១៥កើត ខែពេញបូណ៌មី ដែលមានព្រះចន្ទពេញវង់ក្នុងខែពិសាខប៉ុណ្ណោះ។ ជាមួយគ្នានេះនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ១៩៩៩ អង្គការសហប្រជាជាតិ (UN) ក៏បានប្រកាសទទួលស្គាល់“វិសាខបូជា” ជាពិធីបុណ្យសកលចំពោះបណ្ដាប្រទេសកាន់ព្រះពុទ្ធសាសនា ដែលបុគ្គលិកធ្វើការ និងសាធារណជនអាចប្រារព្ធធ្វើបាននៅទូទាំងពិភពលោកផងដែរ៕

(អត្ថបទ និងរូបភាព៖ នុត សច្ចៈ)



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ អញ្ជើញរាប់បាត្រ*

# សម្តេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យសមាជិកការិយាល័យនយោបាយ បក្សកុម្មុយនីស្តវៀតណាម និងជាលេខាគណៈកម្មាធិការបក្សរដ្ឋធានីហាណូយ ចូលជួបសម្តែងការគួរសម



*ឯកឧត្តម ឌិញ ទៀន ហ្យ៊ុង (Dinh Tien Dung) និងសម្តេចវិបុលសេនាភក្តី សាយ ឈុំ*

នារសៀលថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ១៤:០០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម **ឌិញ ទៀន ហ្យ៊ុង** (Dinh Tien Dung) សមាជិកការិយាល័យនយោបាយបក្សកុម្មុយនីស្តវៀតណាម និងជាលេខាគណៈកម្មាធិការបក្សរដ្ឋធានីហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្តែងការគួរសមនៅវិមានព្រឹទ្ធសភា ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវសេចក្តីសោមនស្សរីករាយ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម **ឌិញ ទៀន ហ្យ៊ុង** ដែលបានដឹកនាំគណៈប្រតិភូ មកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។ ទស្សនកិច្ចរបស់គណៈប្រតិភូបានឆ្លុះបញ្ចាំងអំពី ចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងប្រជាជន និងប្រទេសទាំងពីរ និងបន្តពង្រឹងពង្រីកនូវចំណងមិត្តភាព សាមគ្គីភាព កិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំ និងខ្លាំងក្លាថែមទៀត ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងសម្រាប់ប្រជាជន និងប្រទេសទាំងពីរទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។ ជាមួយគ្នានោះ ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូស្របពេលជាមួយនឹងខួបលើកទី៥៥ ថ្ងៃបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ។

ក្នុងឱកាសនោះ ឯកឧត្តម **ឌិញ ទៀន ហ្យ៊ុង** បានឯកភាពចំពោះប្រសាសន៍របស់សម្តេចប្រធានព្រឹទ្ធសភា ដែលបានលើកឡើងអំពីប្រទេសទាំងពីរបានរៀបចំសកម្មភាពជាច្រើន ដើម្បីអបអរសាទរខួបលើកទី៥៥ ថ្ងៃបង្កើត





*ទិដ្ឋភាពក្នុងពិធីជួបសម្តែងការគួរសម*



*ទិដ្ឋភាពក្នុងពិធីជួបសម្តែងការគួរសម*

ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ។ ជាពិសេស ប្រទេសកម្ពុជាបានរៀបចំពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិរបស់កម្ពុជា ព្រមទាំងកំពុងត្រៀមរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលខាងមុខ។

ឯកឧត្តម **ឌិញ ទៀន ហ្ស៊ឹង** បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ឯកឧត្តមប្រធានរដ្ឋសភាវៀតណាម និងឯកឧត្តមលេខាមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ជូនចំពោះសម្តេចប្រធានព្រឹទ្ធសភា។ ឯកឧត្តមបានអបអរ-សាទរចំពោះសមិទ្ធផលដ៏ធំធេងជាច្រើន ដែលប្រទេសកម្ពុជាសម្រេចបាននាពេលកន្លងទៅ ដោយរក្សាបាននូវស្ថិរភាពនយោបាយ សន្តិសុខ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ព្រមទាំងលើកកម្ពស់កិត្យានុភាពរបស់ប្រទេសកម្ពុជានៅលើឆាកអន្តរជាតិ។ ឯកឧត្តមបានវាយតម្លៃខ្ពស់ចំពោះប្រទេសកម្ពុជា ដែលបានប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដោយជោគជ័យ។ ការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋទទួលបានអត្រាខ្ពស់បំផុតក្នុងតំបន់ ព្រមទាំងបានបើកប្រទេសពេញលេញឡើងវិញយ៉ាងឆាប់រហ័ស។

ឯកឧត្តម **ឌិញ ទៀន ហ្ស៊ឹង** បានសម្តែងនូវសេចក្តីរីក-រាយចំពោះសមិទ្ធផលនានាដែលប្រទេសទាំងពីរ បានរួមចំណែកដល់ការពង្រឹងពង្រីកចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃ។ ឯកឧត្តមសង្ឃឹមថា ព្រឹទ្ធសភាកម្ពុជានឹងបន្តបង្កើនទំនាក់ទំនង និងកិច្ចសហ-ប្រតិបត្តិការបន្ថែមទៀតជាមួយនឹងរដ្ឋសភាវៀតណាម ក្នុងការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ក៏ដូចជាក្នុងការត្រួតពិនិត្យ ការតាមដាន ការជំរុញស្ថាប័នពាក់ព័ន្ធ រួមទាំងពាណិជ្ជករ ក្នុងការអនុវត្តយ៉ាងសកម្មនូវសេចក្តីថ្លែងការណ៍រួម គោលនយោបាយ និងកិច្ចព្រមព្រៀងនានារវាងប្រទេសទាំងពីរ។

សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រសាសន៍ដ៏ល្អប្រពៃរបស់ឯកឧត្តមប្រធានគណៈប្រតិភូ ដែលបានថ្លែងសរសើរចំពោះចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ ព្រមទាំងថ្លែងសរសើរដល់កម្ពុជាដែលគ្រប់គ្រងជំងឺកូវីដ-១៩បានល្អ ព្រមទាំងថ្លែងអំណរគុណឯកឧត្តម ចំពោះការពាំនាំនូវការសួរសុខទុក្ខពីឯកឧត្តមប្រធានរដ្ឋសភាវៀតណាម ជូនចំពោះសម្តេច និងព្រឹទ្ធ-សភា។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវសេចក្តីសប្បាយរីករាយដោយបានឃើញចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសទាំងពីរមានការរីកចម្រើនជាលំដាប់ ដែលមិនគ្រាន់តែបាននាំមកនូវផលប្រយោជន៍ដ៏ធំធេងសម្រាប់ប្រជាជន និងប្រទេសទាំងពីរប៉ុណ្ណោះទេ តែបានរួមចំណែកដល់ការថែរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍរួមរបស់តំបន់ និងអន្តរ-ជាតិប្រកបដោយចីរភាពទៀតផង។

ក្នុងនាមព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបក្ស រដ្ឋាភិបាល កងទ័ព និងប្រជាជនវៀតណាម ដែលបានគាំទ្រដល់បុព្វហេតុ និងយុត្តិធម៌របស់ប្រជាជនកម្ពុជាក្នុងគ្រប់ដំណាក់កាល។ កម្ពុជាប្រកាន់ខ្ជាប់

នូវគោលជំហរឥតងាករេក្នុងការបន្តពូនជ្រំនូវទំនាក់ទំនងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជននៃប្រទេសទាំងពីរតាមពាក្យស្លោក "អ្នកភូមិផងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់វិស័យរឹងមាំយូរអង្វែង"។ កម្ពុជា-វៀតណាម គឺជាអ្នកជិតខាងល្អ បងប្អូនល្អ មិត្តល្អ និងដៃគូល្អ។

ក្នុងនាមព្រឹទ្ធសភា សម្ដេចប្រធានព្រឹទ្ធសភាបានអបអរសាទរចំពោះលទ្ធផលដ៏ធំធេងនៃកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរ។ ពីមុនក៏ដូចបច្ចុប្បន្ន និងទៅអនាគត ព្រឹទ្ធសភាកម្ពុជាបន្តគាំទ្ររាល់កិច្ចសហប្រតិបត្តិការ ដែលចុះហត្ថលេខាដោយរដ្ឋាភិបាលនៃប្រទេសទាំងពីរ និងលើកទឹកចិត្តឱ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរជំរុញការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ចំពោះរាជធានីភ្នំពេញ និងរដ្ឋធានីហាណូយ សម្ដេចប្រធានព្រឹទ្ធសភាបានលើកទឹកចិត្តឲ្យជំរុញកិច្ចសហប្រតិបត្តិការលើវិស័យអាទិភាពនានា និងផ្លាស់ប្ដូរទស្សនកិច្ចមន្ត្រីដឹកនាំ និងមន្ត្រីជំនាញគ្រប់កម្រិត ដើម្បីផ្លាស់ប្ដូរបទពិសោធន៍ក្នុងការគ្រប់គ្រងរាជធានី និងអភិវឌ្ឍជារាជធានីវៃឆ្លាតនាពេលអនាគត។

សម្ដេចប្រធានព្រឹទ្ធសភាបានជម្រាបជូនគណៈប្រតិភូថា កម្ពុជាបានបើកប្រទេសឡើងវិញតាំងពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១។ ចាប់ពីពេលនោះមករហូតដល់បច្ចុប្បន្ន សេដ្ឋកិច្ចកម្ពុជាមានកំណើនជាបន្តបន្ទាប់។ តាមការព្យាករណ៍របស់ ADB សេដ្ឋកិច្ចកម្ពុជាអាចមានកំណើន ៥,៣% នៅឆ្នាំ២០២២ និងមានកំណើន ៦,៥% នៅឆ្នាំ២០២៣។ កម្ពុជាប្ដេជ្ញាការពារសន្តិភាព ធានាម៉ាក្រូសេដ្ឋកិច្ច និងបន្តការចាក់វ៉ាក់សាំងជូនប្រជាជន ដើម្បីបង្កើនភាពស៊ាំក្នុងសហគមន៍ទាំងមូល ដោយចាត់ទុកការចាក់វ៉ាក់សាំងនៅកម្ពុជាជាវ៉ាក់សាំងសេដ្ឋកិច្ច។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា នៅឆ្នាំ២០២២ កម្ពុជានឹងមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ និងឆ្នាំ២០២៣ នឹងមានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៧។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីបង្កលក្ខណសម្បត្តិឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដំណើរការទៅក្នុងបរិយាកាសសន្តិភាព គ្មានអំពើហិង្សា មានលក្ខណៈសេរី និងយុត្តិធម៌ ដែលទាំងអស់គ្នាអាចទទួលយកបាន។

តាមរយៈគណៈប្រតិភូ សម្ដេចប្រធានព្រឹទ្ធសភាបានផ្ដាំផ្ញើសួរសុខទុក្ខដោយសេចក្ដីនឹករលឹក និងសេចក្ដីគោរពស្រឡាញ់ ជូនចំពោះឯកឧត្ដមប្រធានរដ្ឋសភាវៀតណាម និងសូមគោរពអញ្ជើញឯកឧត្ដមប្រធានរដ្ឋសភាវៀតណាម មកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ក្នុងពេលវេលាសមស្របណាមួយ។

សម្ដេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនថ្នាក់ដឹកនាំជាន់ខ្ពស់បក្ស រដ្ឋ និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម សូមមានសុខភាពល្អ និងទទួលបានជ័យជម្នះគ្រប់ភារកិច្ចដ៏ឧត្តុង្គឧត្ដមក្នុងការបម្រើជាតិ។ សម្ដេចបានជូនពរគណៈប្រតិភូមានសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបានភាពរីករាយក្នុងឱកាសស្នាក់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ ទេព មករា រូបភាព៖ គង់ យ៉ារីន)



សម្ដេចប្រធានព្រឹទ្ធសភាថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូវៀតណាម

# សម្ដេចប្រធានព្រឹទ្ធសភាទទួលជួបឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋក្រូអាស៊ី



*ឯកឧត្តម Ivan Velimir Starčević និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៥ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង៩:០០នាទី សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម Ivan Velimir Starčević ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋក្រូអាស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការ និងសម្ដែងការគួរសម នៅវិមានព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តម Ivan Velimir Starčević បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្ដេចប្រធានព្រឹទ្ធសភា ដែលបានចំណាយពេលដ៏មានតម្លៃទទួលជួបឯកឧត្តម។ ឯកឧត្តម បានរំលឹកអំពីជំនួបជាប្រវត្តិសាស្ត្ររវាងអតីតថ្នាក់ដឹកនាំ នៃសាធារណរដ្ឋក្រូអាស៊ី និងព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ ដែលបានរួមចំណែកដ៏សំខាន់ ដើម្បីបង្កើត និងរឹតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរតាំងពីទសវត្សរ៍ទី៥០។

ឯកឧត្តមឯកអគ្គរដ្ឋទូតបានកត់សម្គាល់ឃើញថា ប្រទេសកម្ពុជាមានការផ្លាស់ប្ដូរ និងរីកចម្រើន លើគ្រប់វិស័យយ៉ាងឆាប់រហ័ស។ ឯកឧត្តមមានជំនឿជឿជាក់ថា ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរនឹងកាន់តែរីកចម្រើនថែមទៀត។

តាមរយៈបេសកកម្មការទូតរបស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមឯកអគ្គរដ្ឋទូតត្រៀមខ្លួនជាស្រេចដើម្បីខិតខំប្រឹងប្រែង អស់ពីកម្លាំងកាយចិត្តក្នុងការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរបន្ថែមទៀត។

ក្នុងនាមព្រឹទ្ធសភា និងសម្ដេចផ្ទាល់ សម្ដេចប្រធានព្រឹទ្ធសភាបានស្វាគមន៍ និងអបអរសាទរចំពោះ ឯកឧត្តម Ivan Velimir Starčević ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋក្រូអាស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា។

សម្ដេចប្រធានព្រឹទ្ធសភាមានជំនឿជឿជាក់ថា ក្នុងអាណត្តិបេសកកម្មការទូតរបស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនឹងខិតខំបន្តលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីជាគុណប្រយោជន៍សម្រាប់ប្រជាជនកម្ពុជា និងប្រជាជនក្រូអាស៊ី ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ក្នុងនាមព្រឹទ្ធសភា សម្ដេចប្រធានព្រឹទ្ធសភាបានត្រៀមខ្លួនជានិច្ច ក្នុងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងឯកឧត្តមឯកអគ្គរដ្ឋទូត ដើម្បីរួមចំណែកពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដើម្បីនាំមកនូវផលប្រយោជន៍ទៅវិញទៅមកជូនប្រជាជន និងប្រទេសទាំងពីរ។

សម្ដេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនឯកឧត្តមឯកអគ្គរដ្ឋទូត មានសុខភាពល្អបរិបូរណ៍ និងទទួលបានជោគជ័យចំពោះបេសកកម្មការទូតរបស់ឯកឧត្តម៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្ដេចប្រធានព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម Ivan Velimir Starčević*

# សម្តេចប្រធានព្រឹទ្ធសភាទទួលជួបគណៈប្រតិភូក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា



ឯកឧត្តម វ៉ាំងសង់ អេប្លេ និងសម្តេចវិបុលសេនាភក្តី សាយ ឈុំ

នាព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង៩:៣០នាទី នៅវិមានព្រឹទ្ធសភា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបគណៈប្រតិភូក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជាដឹកនាំដោយឯកឧត្តម **វ៉ាំងសង់ អេប្លេ** (Vincent Eble) សមាជិកព្រឹទ្ធសភាបារាំង និងជាប្រធានក្រុម ក្នុងឱកាសដែលឯកឧត្តម **វ៉ាំងសង់ អេប្លេ** ដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី៦ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវក្តីសោមនស្សរីករាយ និងស្វាគមន៍ដ៏កក់ក្តៅជូនចំពោះឯកឧត្តម **វ៉ាំងសង់ អេប្លេ** និងគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការបំពេញទស្សនកិច្ចរបស់គណៈប្រតិភូនាឱកាសនេះ បានឆ្លុះបញ្ចាំងនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អលើគ្រប់វិស័យដែលមានស្រាប់ និងរួមចំណែកបន្តពង្រឹងពង្រីកឱ្យកាន់តែខ្លាំងក្លាថែមទៀតរវាងកម្ពុជា-បារាំង និងរវាងព្រឹទ្ធសភាទាំងពីរ ដើម្បីនាំមកនូវគុណប្រយោជន៍ដ៏ធំធេង ទាំងពេលបច្ចុប្បន្ន និងពេលអនាគត សម្រាប់ប្រទេស និងប្រជាជនទាំងពីរ។

ក្នុងនាមគណៈប្រតិភូ ឯកឧត្តម **វ៉ាំងសង់ អេប្លេ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចប្រធានព្រឹទ្ធសភា និងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ ប្រកបដោយក្តីរីករាយ និងរាក់ទាក់បំផុតចំពោះគណៈប្រតិភូ។ ឯកឧត្តមបានរំលឹក អំពីការបង្កើតក្រុមមិត្តភាពព្រឹទ្ធសភាបារាំងតាំងពីឆ្នាំ១៩៩១ ហើយបច្ចុប្បន្នក្រុមមិត្តភាពព្រឹទ្ធសភាបារាំងបានផ្តោតការងារលើប្រធានបទជាច្រើន ជាពិសេសកិច្ចសហប្រតិបត្តិការខាងផ្នែកអភិរក្ស និងអភិវឌ្ឍន៍លើវិស័យបេតិកភណ្ឌវប្បធម៌។ តាមរយៈជំនួបនានាជាមួយនឹងថ្នាក់ដឹកនាំ និងការអញ្ជើញទៅទស្សនានៅតំបន់នានា គណៈប្រតិភូក៏បានចាប់អារម្មណ៍លើវិស័យអប់រំ ដោយនៅខេត្តសៀមរាប គណៈប្រតិភូបានជួបខាងផ្នែកវិស័យអប់រំ និងបានទៅទស្សនាសាលាដេកាត នៅរាជធានីភ្នំពេញ។

ឯកឧត្តម **វ៉ាំងសង់ អេប្លេ** បានមានប្រសាសន៍ថា នៅឆ្នាំនេះប្រទេសទាំងពីរកំពុងតែរៀបចំការបោះឆ្នោតដូចគ្នា។ នៅប្រទេសបារាំងទើបតែបានបោះឆ្នោតជ្រើសរើសប្រធានាធិបតីរួច រីឯប្រទេសកម្ពុជាក៏កំពុងត្រៀមរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥





ទិដ្ឋភាពក្នុងពិធីជួបសម្តែងការគួរសម

និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ អាណត្តិទី៧ ដូចនេះប្រទេសទាំងពីរអាចពិភាក្សាគ្នាអំពីលទ្ធិប្រជាធិបតេយ្យ។

សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រសាសន៍ដ៏ល្អប្រពៃរបស់ឯកឧត្តមប្រធានក្រុម។ សម្ដេចបានរំលឹកថា ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥២ ក្រោមស្នាព្រះហស្តព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** “ព្រះបរមរតនកោដ្ឋ” និងថ្នាក់ដឹកនាំបារាំងជំនាន់មុនៗ ឆ្នាំនេះជាខួបលើកទី៧០ នៃការបង្កើតទំនាក់ទំនងការទូតរវាងសាធារណរដ្ឋបារាំង និងព្រះរាជាណាចក្រកម្ពុជា។

សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវសេចក្ដីសប្បាយរីករាយ និងបានកត់សម្គាល់ដោយការពេញចិត្តចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគីរវាងប្រទេសទាំងពីរ ដែលមានការរីកចម្រើនលើគ្រប់វិស័យឥតឈប់ឈរ។ ទំនាក់ទំនងដ៏ល្អនេះស្ដែងឡើងតាមរយៈការផ្លាស់ប្ដូរទស្សនកិច្ចទៅវិញទៅមករវាងប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ថ្នាក់ដឹកនាំសភា មន្ត្រីជាន់ខ្ពស់គ្រប់លំដាប់ថ្នាក់ និងការផ្លាស់ប្ដូររវាងប្រជាជន និងប្រជាជនជាញឹកញាប់។ ទន្ទឹមនេះ ប្រទេសទាំងពីរបានបន្តគាំទ្រគ្នាជាបន្តបន្ទាប់នៅក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ ជាពិសេសក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ។

ក្នុងនាមព្រឹទ្ធសភា ប្រជាជនកម្ពុជា សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះរដ្ឋាភិបាលបារាំង ដែលបានដើរតួនាទីស្នូលក្នុងដំណើរការស្វែងរកសន្តិភាព ការផ្សះផ្សាបង្រួបបង្រួមជាតិនៅកម្ពុជា រហូតសម្រេចបាននូវកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅឆ្នាំ១៩៩១ និងបានបញ្ជូនកងកម្លាំងរក្សាសន្តិភាពរបស់បារាំង ចូលរួមជាមួយនឹងអាជ្ញាធរបណ្ដោះអាសន្នអង្គការសហប្រជាជាតិនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមប្រជាជនកម្ពុជា សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនបារាំង ដែលបានផ្ដល់ជំនួយឥតសំណង កម្ចីអធិបតេយ្យ និងកម្ចីមិនអធិបតេយ្យលើវិស័យជាច្រើននៅព្រះរាជាណាចក្រកម្ពុជា។ ជំនួយឥតសំណង ហិរញ្ញប្បទានរបស់បារាំង និងការផ្លាស់ប្ដូរពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍រវាងបារាំង-កម្ពុជា បានរួមចំណែកដ៏សំខាន់ដល់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច នៅកម្ពុជា ជួយលើកកម្ពស់ជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ឆ្លើយតបនឹងប្រសាសន៍របស់ឯកឧត្តម **ឡាំងសង់ អេម្លេ** អំពីលទ្ធិប្រជាធិបតេយ្យ សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជានឹងរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅឆ្នាំ២០២២ និងរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ អាណត្តិទី៧ នៅឆ្នាំ២០២៣។ គណបក្សនយោបាយដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃមានចំនួន៤៥ គណបក្ស។ គណបក្សនយោបាយចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ មានចំនួន១៧គណបក្ស។ ប្រទេសកម្ពុជាខិតខំរៀបចំការបោះឆ្នោតទាំងពីរនេះឱ្យប្រព្រឹត្តទៅបានក្នុងបរិយាកាសសន្តិភាព គ្មានអំពើហិង្សា មានលក្ខណៈសេរី និងយុត្តិធម៌ ហើយទាំងអស់គ្នាអាចទទួលយកបាន។

ក្នុងឱកាសនោះ ឯកឧត្តម **ឡាំងសង់ អេម្លេ** បានបញ្ជាក់ថា ដោយសារតែទំនាក់ទំនងដ៏យូរអង្វែងរវាងព្រឹទ្ធសភា នៃប្រទេសទាំងពីរ សភានៃប្រទេសទាំងពីរមានការពិភាក្សាគ្នាដោយចិត្តស្មោះ។ ឯកឧត្តមបានសម្ដែងនូវសេចក្ដីរីករាយដែលបានមើលឃើញទិដ្ឋភាពបែបនេះ។ តាមរយៈដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនាពេលនេះ គឺស្របពេលដែលប្រទេសទាំងពីរប្រារព្ធខួបលើកទី៧០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ។ មិត្តភាពកម្ពុជា-បារាំង ជាមិត្តភាពដែលមានវ័យចំណាស់យូរអង្វែង និងជាប្រវត្តិសាស្ត្រ ព្រមទាំងមានសារសំខាន់តាំងពីអតីតកាល បច្ចុប្បន្ន និងទៅថ្ងៃអនាគតទៀត។

ឯកឧត្តម **ឡាំងសង់ អេម្លេ** បានកត់សម្គាល់ថា តាមរយៈដំណើរទស្សនកិច្ចរបស់គណៈប្រតិភូរយៈពេលប៉ុន្មានថ្ងៃនេះ ឯកឧត្តមសង្កេតឃើញថា នៅក្នុងស្ថាប័នសាធារណៈនៅប្រទេសកម្ពុជាមានការអនុវត្តស្រដៀងគ្នាទៅនឹងប្រទេសបារាំងដែរ ដូចនេះភាពស្រដៀងគ្នានេះហើយ ដែលធ្វើឱ្យប្រទេសទាំងពីរពិភាក្សាគ្នាដោយបើកចំហ និងមានភាពស្មោះត្រង់ ព្រមទាំងធ្វើឱ្យទំនាក់ទំនងកាន់តែខិតជិត និងស្និទ្ធស្នាលថែមទៀត។

សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណដល់រដ្ឋាភិបាលបារាំង ដែលបានជួយអភិវឌ្ឍធនធានមនុស្សរបស់កម្ពុជា តាមរយៈការផ្ដល់អាហារូបករណ៍ទៅសិក្សានៅសាធារណរដ្ឋបារាំង។ ធនធានមនុស្សដែលបារាំងបានជួយបណ្ដុះបណ្ដាល បាននឹងកំពុងរួមចំណែកយ៉ាងសំខាន់នៅក្នុងការជួយកសាង និងអភិវឌ្ឍសង្គមទាំងក្នុងវិស័យសាធារណៈ និងឯកជន។

សម្ដេចប្រធានព្រឹទ្ធសភាបានជម្រាបគណៈប្រតិភូថា ប្រទេសកម្ពុជា ជាប្រទេសសមាជិកប្រើប្រាស់ភាសាបារាំង បានខិតខំលើកកម្ពស់ការបណ្ដុះបណ្ដាលភាសាបារាំងយ៉ាងទូលំទូលាយ។ បច្ចុប្បន្ននេះ កម្ពុជាមានសាលាបណ្ដុះបណ្ដាលភាសាបារាំង ដូចជា៖ សាលាដេកាតនៅភ្នំពេញថ្នាក់ពីរភាសា វិទ្យាស្ថានភាសាបារាំងនៅកម្ពុជា និងការបណ្ដុះបណ្ដាលភាសាបារាំងនៅតាមគ្រឹះស្ថានសិក្សារដ្ឋចាប់តាំងពីថ្នាក់មធ្យមដល់ថ្នាក់ឧត្ដមសិក្សា។ ការខិតខំយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបណ្ដុះបណ្ដាលផ្នែកភាសាបារាំងដល់យុវជនជំនាន់ក្រោយ ក្នុងគោលបំណងថែរក្សាចំណងមិត្តភាពល្អរវាងប្រជាជន និងប្រទេសយើងទាំងពីរ ថែរក្សាមរតកពីបារាំងជាប្រទេសនិយាយភាសាបារាំង និងជំរុញឱ្យការប្រើប្រាស់ភាសាបារាំងកាន់តែទូលំទូលាយយូរអង្វែងនៅកម្ពុជា។ ទន្ទឹមនឹងនេះ កម្ពុជាក៏ទទួលមរតករបស់បារាំងរហូតមកដល់បច្ចុប្បន្ននៅក្នុងប្រព័ន្ធយុត្តិធម៌ និងរដ្ឋបាលសាធារណៈ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា ផ្អែកលើប្រវត្តិសាស្ត្រនៃទំនាក់ទំនងប្រទេសទាំងពីរ បារាំងស្គាល់កម្ពុជាច្បាស់ជាងប្រទេសណាៗទាំងអស់។ កម្ពុជាគ្រប់កាលៈទេសៈចាត់ទុកបារាំងជាមិត្តល្អ ដៃគូល្អ ហើយខិតខំថែរក្សាចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ជាពិសេសខិតខំថែរក្សាមរតកបារាំងដែលបានចាក់ឫសគល់នៅក្នុងសង្គមកម្ពុជា។ សម្ដេចមានជំនឿជឿជាក់ថាបារាំងបន្តគាំទ្រកម្ពុជា ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចក្នុងរយៈពេលយូរអង្វែង។ ជាងនេះទៀត បារាំងនឹងជួយគាំទ្របុព្វហេតុត្រឹមត្រូវ យុត្តិធម៌របស់កម្ពុជាក្នុងការដឹកនាំប្រទេស និងនៅលើឆាកអន្តរជាតិ។

ក្នុងស្មារតីខាងលើនេះ សម្ដេចប្រធានព្រឹទ្ធសភាបានស្នើ៖ ១-ព្រឹទ្ធសភាបារាំងបន្តគាំទ្រឱ្យមានការផ្លាស់ប្ដូរទស្សនកិច្ចគ្រប់កម្រិតឡើងវិញ។ ២-ជួយគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌអន្តរសភា ជាពិសេសក្នុងក្របខ័ណ្ឌសភានិយាយភាសាបារាំង។ ៣-ព្រឹទ្ធសភាបារាំងជួយគាំទ្រ និងការពារធម្មានុរូបរបស់កម្ពុជានៅក្នុងគណៈកម្មការនយោបាយ នៃសភានិយាយភាសាបារាំង។

តាមរយៈឯកឧត្ដម និងគណៈប្រតិភូ សម្ដេចប្រធានព្រឹទ្ធសភាបានផ្ដាំផ្ញើសួរសុខទុក្ខដោយក្ដីគោរពរាប់អាន សេចក្ដីស្រឡាញ់ ដោយមិត្តភាពដ៏ជ្រាលជ្រៅចំពោះឯកឧត្ដមប្រធានព្រឹទ្ធសភាបារាំង និងសូមអញ្ជើញឯកឧត្ដមប្រធានព្រឹទ្ធសភាមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា តាមពេលវេលាសមស្រប។

ឯកឧត្ដម **ឡាំងសង់ អេប្លេ** បានថ្លែងអំណរគុណចំពោះប្រសាសន៍ដ៏ល្អៗរបស់សម្ដេចប្រធានព្រឹទ្ធសភា។ ក្នុងនាមប្រធានក្រុមមិត្តភាព និងឯកឧត្ដម លោកជំទាវ ព្រមទាំងសហការីសូមធានាអះអាងថា នឹងខិតខំបន្តគាំទ្រនូវសំណើរបស់សម្ដេចដែលបានលើកឡើង ហើយនឹងជួយជំរុញក្នុងកិច្ចសហប្រតិបត្តិការនេះ។ ជាការឆ្លើយតបនឹងការអញ្ជើញរបស់សម្ដេចប្រធានព្រឹទ្ធសភា ចំពោះឯកឧត្ដមប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋបារាំងមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្ដមនឹងពាំនាំសារនេះជូនប្រធានព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង។

សម្ដេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនគណៈប្រតិភូសូមមានសុខភាពល្អបរិបូរណ៍ និងទទួលបានភាពរីករាយក្នុងការស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្ដេចប្រធានព្រឹទ្ធសភា ថតរូបអនុស្សាវរីយជាមួយឯកឧត្ដម ឡាំងសង់ អេប្លេ*

# ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន សំណេះសំណាល ក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង នៅខេត្តកណ្ដាល





*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន សំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្រុកកៀនស្វាយ*

កាលពីថ្ងៃទី៤ ដល់ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា អមដំណើរដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ (ខេត្តកណ្ដាល) បានអញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង នៅស្រុកកោះធំ ស្រុកស្អាង ក្រុងតាខ្មៅ ស្រុកកណ្ដាលស្ទឹង ស្រុកអង្គស្នួល ស្រុកពញាឮ ស្រុកមុខកំពូល ស្រុកខ្សាច់-កណ្ដាល ស្រុកល្វាឯម ស្រុកកៀនស្វាយ និងស្រុកលើក-ដែក ខេត្តកណ្ដាល។

ក្នុងពិធីសំណេះសំណាលនោះ រៀបចំឡើងដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន និងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ការងារសន្តិសុខសណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការត្រៀមលក្ខណៈសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

មានប្រសាសន៍នៅតាមស្រុកនីមួយៗឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** តែងតែបានលើកទឹកចិត្តដល់អាជ្ញាធរក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ត្រូវខិតខំអនុវត្តតួនាទីរបស់ខ្លួន និងបំពេញការងារឱ្យបានល្អជូនប្រជាជន ជាពិសេសការទប់ស្កាត់ជំងឺកូវីដ-១៩ ការរួមគ្នាអនុវត្តគោល-នយោបាយវិមជ្ឈការឱ្យបានត្រឹមត្រូវ និងការត្រៀមលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីត្រៀមការបោះឆ្នោតខាងមុខ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានសង្កត់ធ្ងន់ថា ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលបច្ចុប្បន្ន





*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន សំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ក្រុងតាខ្មៅ*




ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន សំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្រុកពញាឮ

ដែលមានសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បានធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាព ពេញលេញដូចសព្វថ្ងៃ ដូច្នេះទោះបីស្ថិតក្នុងតម្លៃណាក៏ដោយ យើងត្រូវតែការពារឱ្យបាននូវសុខសន្តិភាពនេះ។ តាមរយៈសន្តិភាព ប្រទេសយើងសម្រេចបាននូវសមិទ្ធផលថ្មីៗជាច្រើននៅទូទាំងប្រទេស ដូចនេះសូមអាជ្ញាធរមូលដ្ឋានធ្វើយ៉ាងណាថែរក្សាសមិទ្ធផលទាំងអស់នោះ ហើយខិតខំរួបរួមសាមគ្គីគ្នា រួមគ្នាគិត រួមគ្នាធ្វើ ដើម្បីឱ្យប្រទេសជាតិ ក៏ដូចជានៅមូលដ្ឋានយើងមានការអភិវឌ្ឍ និងសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ត្រូវគិតពីយុវជនបន្តវេន ដោយធ្វើការផ្ទេរចំណេះ ជំនាញជូនពួកគាត់ ក៏ដូចជាការបង្ហាញពីសមិទ្ធផល និងសមត្ថភាពថ្នាក់ដឹកនាំដែលបានដឹកនាំប្រទេសឆ្ពោះទៅកាន់ការរីកចម្រើន ដែលធ្វើឱ្យពិភពលោកមានការកោតសរសើរ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានបំពេញតួនាទី ភារកិច្ច ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋបានល្អប្រសើរ និងបានចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ឯកឧត្តមកិត្តិសង្គហបណ្ឌិត បានធ្វើការផ្ដាំផ្ញើដល់អាជ្ញាធរទាំងអស់ត្រូវថែរក្សាសុខភាពរបស់ខ្លួន និងជួយផ្សព្វផ្សាយដល់បងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន សូមឱ្យប្រុងប្រយ័ត្នខ្ពស់ជាប់ជានិច្ច និងថែរក្សាសុខភាពកុំឱ្យឆ្លងជំងឺកូវីដ-១៩ ដោយអនុវត្តនូវវិធានការ៣កុំ ៣ការពារ ព្រមទាំងទៅទទួលការចាក់វ៉ាក់សាំងទាំងដូសមូលដ្ឋាន និងដូសជំរុញឱ្យបានគ្រប់ៗគ្នា៕

(អត្ថបទ៖ ធុន គីមជី រូបភាព៖ គង់ យ៉ារីន)





ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន សំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្រុកមុខកំពូល

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាសំណេះសំណាលជាមួយនឹង ប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២៨ ខែមេសា ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខមន្ត្រី កងកម្លាំង និងអាជ្ញាធរ សង្កាត់អូរបឬស្សីទី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២២ គណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានអញ្ជើញដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធសពសម្ដេចឧត្តមទេពញាណ **ហ៊ុន ណេង** ប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ នៃរដ្ឋសភា និងជាតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម នៅគេហដ្ឋានស្ថិតក្នុងភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម។




❈នាព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីបញ្ចុះសពសម្ដេចឧត្តមទេពញាណ **ហ៊ុន ណេង** ប្រធានគណៈកម្មការទី៤ នៃរដ្ឋសភា និងជាអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម នៅវត្តសុវណ្ណគិរីរតនៈភ្នំប្រុស ភូមិត្រពាំងចារ ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា និងលោកជំទាវ បានអញ្ជើញជាអធិបតីភាពក្នុងពិធីរំលឹកទិវាជាតិនៃការចងចាំ ២០ ឧសភា ជាថ្ងៃដែលប្រជាជនកម្ពុជាគ្រប់រូបចងចាំមិនអាចបំភ្លេចបានក្នុងរបបកម្ពុជាប្រជាធិតេយ្យ ឬហៅថា របបប្រល័យពូជសាសន៍ ប៉ុល ពត (១៧ មេសា ១៩៧៥ - ៦ មករា ១៩៧៩) នៅក្នុងភូមិរលួស សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ។



❈នារសៀលថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ ឯកឧត្តម កិត្តិសង្គហបណ្ឌិត **ទេព ខុន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរ ក្រុមប្រឹក្សាឃុំ និងពិនិត្យទីតាំងសម្រាប់សាងសង់ព្រះវិហារ នៅវត្តអូរសោម ស្ថិតក្នុងឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់។



❈នាល្ងាចថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម កិត្តិសង្គហបណ្ឌិត **ទេព ខុន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញពិសាអាហារសាមគ្គីជាមួយក្រុមសមាជិកាព្រឹទ្ធសភា នៅក្រុងតាខ្មៅ ខេត្តកណ្តាល។



❈នាព្រឹកថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ គណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខុន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមសន្តិបណ្ឌិត **ឌុល គឿន** តំណាងរាស្ត្រមណ្ឌលខេត្តកណ្តាល នីតិកាលទី៦ នៃរដ្ឋសភា នៅភូមិគ្រឹះលេខ៧២ ភូមិមិត្តភាព សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ។



# គណៈកម្មការទី១ព្រឹទ្ធសភាសំណេះសំណាលអាជ្ញាធរស្រុក ក្រុមប្រឹក្សាឃុំ នៃស្រុកមណ្ឌលសីមា ខេត្តកោះកុង




*គណៈកម្មការទី១ព្រឹទ្ធសភាពិភាក្សាការងារជាមួយនឹងអាជ្ញាធរខេត្តកោះកុង*

ដើម្បីត្រៀមខ្លួនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នាពេលខាងមុខ អាជ្ញាធរពាក់ព័ន្ធ និងក្រុមប្រឹក្សាឃុំ ត្រូវបន្តយកចិត្តទុកដាក់អនុវត្តការងារទៅតាមតួនាទី ភារកិច្ច ឱ្យកាន់តែសកម្ម យកចិត្តទុកដាក់លើការងាររក្សាការពារសុខសុវត្ថិភាពជូនប្រជាពលរដ្ឋក្នុងស្រុក ឃុំ ព្រមទាំងបន្តចូលរួមសាមគ្គីភាពផ្ទៃក្នុង ប្រមូលផ្ដុំកម្លាំង វិធានការ និងមធ្យោបាយសរុប។

ការលើកឡើងខាងលើនេះត្រូវបានឯកឧត្តម **យ៉េង សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា មានប្រសាសន៍ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេត នៃព្រឹទ្ធសភា (គណៈកម្មការទី១) អញ្ជើញជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរស្រុក ក្រុមប្រឹក្សាឃុំចំនួន៣ នៃស្រុកមណ្ឌលសីមា ខេត្តកោះកុង ដោយមានការចូលរួមពីប្រធានក្រុមប្រឹក្សាខេត្ត អភិបាលរងខេត្ត និងនាយរងរដ្ឋបាលសាលាខេត្តកោះកុង សរុប១១០នាក់ កាលពីព្រឹកថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២ នៅសាលមហោស្រពខេត្តកោះកុង ស្ថិតនៅក្នុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

បន្ទាប់ពីលោក **ប្រាក់ វិចិត្រ** អភិបាលស្រុកមណ្ឌលសីមា និងក្រុមប្រឹក្សាឃុំ នៃស្រុកមណ្ឌលសីមា ព្រមទាំងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក បានឡើងធ្វើសេចក្ដីរាយការណ៍អំពីវឌ្ឍនភាពការងារ បញ្ហា



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

ប្រឈម និងសំណូមពររួចមក ឯកឧត្តម **យ៉ង់ សែម** បាន សម្ដែងការកោតសរសើរ លើកទឹកចិត្ត និងវាយតម្លៃខ្ពស់ ចំពោះអាជ្ញាធរ និងក្រុមប្រឹក្សាឃុំទាំងអស់ ដែលកន្លងមក បានប្រឹងប្រែងដោះស្រាយរាល់បញ្ហាលំបាកនៅក្នុងភូមិ សាស្ត្ររបស់ខ្លួន និងបានយកចិត្តទុកដាក់ចំពោះការងារ បម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ និងបំពេញការងារ រក្សានូវសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈនៅក្នុងស្រុក ឃុំ បានល្អប្រសើរ ប្រកបដោយជំនឿទុកចិត្តពីសំណាក់បងប្អូន ប្រជាពលរដ្ឋ។

ពិធីសំណេះសំណាលនេះរៀបចំឡើង ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មាននានាពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ ស្រុក ឃុំ រួមមាន៖ ១-ផែនការសកម្មភាពរដ្ឋបាលឃុំ ដើម្បី បង្កើតជំនឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ។ ២-ការអនុ-វត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព បញ្ហា ប្រឈម។ ៣-មណ្ឌលបណ្ដុះបណ្ដាលកម្រិតវប្បធម៌ក្នុង ស្រុកមណ្ឌលសីមា (សហគមន៍ បឋមសិក្សា អនុវិទ្យាល័យ-វិទ្យាល័យ)។ ៤-ការប្រកបអាជីវកម្ម និងជីវភាពរស់នៅរបស់ ប្រជាពលរដ្ឋក្នុងឃុំ។ ៥-ការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋក្នុង ឃុំ ទៅចូលរួមបោះឆ្នោត។ ៦-ការផ្សព្វផ្សាយជូនដល់ប្រជា-ពលរដ្ឋឱ្យចូលរួមទប់ស្កាត់ជំងឺកូវីដ-១៩។ ៧-ស្ដាប់បញ្ហា ប្រឈម និងសំណូមពរជុំវិញការអនុវត្តតួនាទីរបស់ក្រុម ប្រឹក្សាឃុំ ស្រុក។ ៨-ប្រមូលផ្ដុំវិធានការសរុប មធ្យោបាយ សរុប និងកម្លាំងសរុប ឆ្ពោះទៅធានាភាពជោគជ័យក្នុងការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។ ជាមួយគ្នានេះដែរ គណៈប្រតិភូគណៈកម្មការ ទី១ព្រឹទ្ធសភា ក៏បានជូនវត្ថុអនុស្សាវរីយដល់អាជ្ញាធរស្រុក និងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ ព្រមទាំងថវិកាមួយ ចំនួន។

ក្រៅពីជួបសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំ ស្រុក និងឃុំ គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភា បាន អញ្ជើញថ្វាយបង្គំព្រះសង្ឃ ព្រមទាំងនាំយកទេយ្យវត្ថុប្រគេន ដល់ព្រះសង្ឃ និងចែកអំណោយដល់យាយជីតាជី ដោយ ក្នុងម្នាក់ៗទទួលបានក្រណាត់ស១ដុំ ថវិកា២ម៉ឺនរៀល នៅ វត្តជោតៈញាណ ស្ថិតនៅក្រុងខេមរភូមិន្ទ ខេត្តកោះកុង ព្រម-ទាំងចែកអំណោយជូនដល់បងប្អូនប្រជាពលរដ្ឋ ដែលមាន ជីវភាពខ្វះខាតចំនួន១០គ្រួសារ ដោយក្នុងមួយគ្រួសារៗ ទទួលបាននូវ៖ មី១កេស ត្រីខ១យួរ ទឹកត្រី១យួរ ទឹកស៊ីអ៊ីវ ១យួរ ស្ករ-ស ទឹកដោះគោ ម៉ាស់១ប្រអប់ និងថវិកា៤ម៉ឺន-រៀល៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)



*គណៈកម្មការទី១ព្រឹទ្ធសភាថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរខេត្តកោះកុង*

# គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភាសំណេះសំណាល អតីតយុទ្ធជន និវត្តជន ចាស់ជរា ជនពិការ និងយុវជន នៅខេត្តក្រចេះ




*គណៈកម្មការទី១ព្រឹទ្ធសភាសំណេះសំណាលអតីតយុទ្ធជន និវត្តជន ចាស់ជរា ជនពិការ និងយុវជន នៅខេត្តក្រចេះ*

នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត នៃព្រឹទ្ធសភា (គណៈកម្មការទី១) ដឹកនាំដោយឯកឧត្តម **យ៉េង សែម** ប្រធានគណៈកម្មការ បានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខអតីតយុទ្ធជន និវត្តជន ចាស់ជរា ជនពិការ និងយុវជន នៅសាលមហោស្រព ខេត្តក្រចេះ។

ក្នុងឱកាសនោះ លោកអភិបាលក្រុងក្រចេះបានឡើងរាយការណ៍អំពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈម ព្រមទាំងមតិសំណេះសំណាល និងសួរសុខទុក្ខរបស់គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភា។

មានប្រសាសន៍សំណេះសំណាលនាពេលនោះ ឯកឧត្តម **យ៉េង សែម** បាននាំយកនូវការសួរសុខទុក្ខពីថ្នាក់ដឹកនាំព្រឹទ្ធសភាជូនចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងខេត្តក្រចេះ។ ឯកឧត្តមបានបញ្ជាក់ថា ពិធី



*លោកអភិបាលក្រុងក្រចេះឡើងរាយការណ៍*





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលអតីតយុទ្ធជន និវត្តជន ចាស់ជរា ជនពិការ និងយុវជន នៅខេត្តក្រចេះ*

នេះរៀបចំឡើងដើម្បីជាការដឹងគុណចំពោះវីរជន អតីតយុទ្ធជន និវត្តជន ចាស់ជរា ជនពិការ និងយុវជនទាំងអស់ ដែលបានលះបង់គ្រប់បែបយ៉ាងដើម្បីប្រទេសជាតិ។ ឯកឧត្តម បានជំរុញដល់ប្រជាពលរដ្ឋទាំងអស់ត្រូវខិតខំអប់រំកូនចៅរបស់ខ្លួនឱ្យខិតខំរៀន ពីព្រោះថា មានតែការសិក្សាទេដែលអាចជួយឱ្យប្រទេសជាតិមានការរីកចម្រើនបាន ដូច្នេះត្រូវខិតខំបណ្ដុះបណ្ដាលក្មួយៗដែលជាទំពាំងស្នងឫស្សី។

ឯកឧត្តម **យ៉ង់ សែម** បានជំរុញ និងលើកទឹកចិត្តដល់អាជ្ញាធរទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ជាមួយនឹងអតីតយុទ្ធជន និវត្តជន ចាស់ជរា ជនពិការ និងយុវជន និងត្រូវត្រៀមលក្ខណៈសម្បត្តិឱ្យបានគ្រប់គ្រាន់ សម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០២៣ ដើម្បីជ្រើសរើសនូវថ្នាក់ដឹកនាំដ៏ល្អសម្រាប់អភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនបន្ថែមទៀត។

ក្នុងឱកាសនោះគណៈប្រតិភូបានចែកក្រមា និងថវិកាជូនអតីតយុទ្ធជន និវត្តជន ចាស់ជរា ជនពិការ និងយុវជន ចំនួន១៥៥នាក់ ដោយក្នុងម្នាក់ៗទទួលបាន ថវិកាចំនួន ៥ម៉ឺនរៀល ក្រមាចំនួន១ និងសៀវភៅរដ្ឋធម្មនុញ្ញ ចំនួនមួយក្បាល។

ក្រៅពីជួបសំណេះសំណាល គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញថ្វាយបង្គំព្រះសង្ឃ និងនាំយកនូវទេយ្យវត្ថុ និងបច្ច័យមួយចំនួនប្រគេនដល់ព្រះសង្ឃ នៅវត្តវិហារធំសសរ១០០ ស្ថិតក្នុងស្រុកសំបូរ និងវត្តរកាកណ្ដាល ស្ថិតក្នុងក្រុងក្រចេះ ខេត្តក្រចេះ៕

(អត្ថបទ និងរូបភាព៖ ធុន គឹមជី)





ឯកឧត្តម យ៉ង់ សែម ជូនអំណោយដល់
អតីតយុទ្ធជន និវត្តជន ចាស់ជរា ជនពិការ និងយុវជន





គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភា នាំយកទេយ្យវត្ថុប្រគេនដល់ព្រះសង្ឃ នៅវត្តវិហារធំសសរ១០០ និងវត្តរកាកណ្ដាល នៅខេត្តក្រចេះ

# លោកជំទាវ មាន សំអាន សំណេះសំណាលថ្នាក់ដឹកនាំជាស្ត្រី នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង




*លោកជំទាវ មាន សំអាន សំណេះសំណាលថ្នាក់ដឹកនាំជាស្ត្រីនៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង*

នាព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងជាអនុប្រធានទី១ សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងសមាជិកាក្រុមប្រឹក្សាឃុំ សមាជិកាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងថ្នាក់ដឹកនាំជាស្ត្រីនៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ដោយមានការអញ្ជើញចូលរួមសរុបចំនួន២៣០នាក់ នៅសាលប្រជុំសាលាស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

បន្ទាប់ពីបានស្តាប់មតិស្វាគមន៍របស់ឯកឧត្តមអភិបាលរងខេត្ត និងលោកអភិបាលស្រុកទឹកផុសធ្វើសេចក្តីរាយការណ៍រួចមក លោកជំទាវ **មាន សំអាន** បានមានប្រសាសន៍ពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងលោកជំទាវសង្គហបណ្ឌិត **ម៉ែន សំអន** ប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ប្រកបដោយក្តីនឹករលឹក និងគិតគូរដោយយកចិត្តទុកដាក់ខ្ពស់ អំពីសុខទុក្ខ សុខុមាលភាព និងជីវភាពរស់នៅរបស់បងប្អូនគ្រប់ពេលវេលា។

លោកជំទាវ **មាន សំអាន** បានសម្តែងនូវសេចក្តីរីករាយ និងមានមោទនភាពយ៉ាងខ្លាំងចំពោះបងប្អូនស្ត្រីទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងច្រើននៅក្នុងសកម្មភាពនៃការដឹកនាំ និងបានបំពេញតួនាទី ភារកិច្ច តាមជំនាញរៀងៗខ្លួន ជាពិសេសមានការចូលរួម មានស្មារតីទទួលខុសត្រូវខ្ពស់ ទើបទទួលបានសមិទ្ធផលយ៉ាងល្អប្រសើរ ធ្វើឱ្យស្រុកទឹកផុសមានការអភិវឌ្ឍ និងការរីកចម្រើនគួរឱ្យកត់សម្គាល់។ លោកជំទាវបានជម្រាបអំពីប្រវត្តិ សកម្មភាព និងសមិទ្ធផលសំខាន់ៗរបស់សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និង



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*



ទិដ្ឋភាពក្នុងពិធីសំណេះសំណាល

អភិវឌ្ឍន៍ ក្នុងរយៈពេលជាង៤៣ឆ្នាំកន្លងទៅ និងសមិទ្ធផលធំៗប្រកបដោយមោទនភាពរបស់រាជរដ្ឋាភិបាល ជាពិសេសក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រទេសមានសុខសន្តិភាព មានស្ថិរភាពនយោបាយល្អ មានការអភិវឌ្ឍលើគ្រប់វិស័យ និងការទប់ស្កាត់នូវការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ បានយ៉ាងល្អ ដែលបានធ្វើឱ្យកម្ពុជាក្លាយជាប្រទេសដែលឈរលេខ២ ក្នុងនាមជាប្រទេសមានសមត្ថភាពងើបចេញពីកូវីដ-១៩ លឿនជាងគេនៅលើពិភពលោក ។

លោកជំទាវ **មាន សំអាន** បានបញ្ជាក់ថា ស្ត្រីកម្ពុជាមានចំនួនច្រើនជាង ៥២% នៃប្រជាជនទាំងមូល ហើយបានដើរតួនាទីសំខាន់នៅក្នុងវិស័យកសិកម្ម ឧស្សាហកម្ម សេដ្ឋកិច្ចក្រៅប្រព័ន្ធ ផ្នែកសេវាកម្ម ។ល។ ហើយបានរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើន ដោយហេតុដូច្នេះ ទើបរាជរដ្ឋាភិបាលបានកំណត់ច្បាស់ថាស្ត្រីគឺជា "ឆ្អឹងខ្នង នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច"។ លោកជំទាវបានរំលឹកផងដែរអំពីកាលបរិច្ឆេទ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដែលកាន់តែខិតជិតមកដល់ហើយ ហេតុនេះសូមអាជ្ញាធរស្រុក និងសមាជិកាក្រុមប្រឹក្សាឃុំទាំងអស់ត្រូវតែក្តាប់ឱ្យជាប់រាល់ផែនការសកម្មភាពឆ្ពោះទៅកាន់ការបោះឆ្នោត ដែលថ្នាក់លើបានដាក់ចុះ និងជំរុញឱ្យប្រជាពលរដ្ឋត្រូវត្រៀមលក្ខណសម្បត្តិឱ្យបានគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ខាងមុខ ឱ្យបានទាំងអស់គ្នា។ ក្រៅពីនេះលោកជំទាវបានផ្តាំផ្ញើដល់បងប្អូនជានារីទាំងអស់សូមបន្តផ្សព្វផ្សាយជូនប្រជាពលរដ្ឋទាំងអស់បន្តប្រុងប្រយ័ត្នខ្ពស់ជាប់ជានិច្ច ថែរក្សាសុខភាពកុំឱ្យឆ្លងជំងឺកូវីដ-១៩ ដោយអនុវត្តនូវវិធានការសុខាភិបាល ៣កុំ ៣ការពារ និងសូមទៅទទួលការចាក់វ៉ាក់សាំងដូសមូលដ្ឋាន និងដូសជំរុញឱ្យបានគ្រប់ៗគ្នា៕

(អត្ថបទ និងរូបភាព៖ នុត សច្ចៈ)



លោកជំទាវ មាន សំអាន ថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំជាស្ត្រីនៅស្រុកទឹកផុស

# គណៈកម្មការទី១០ព្រឹទ្ធសភាឈ្វេងយល់ការអនុវត្តច្បាប់ និងការងារតាមវិស័យជាសមត្ថកិច្ចនៅខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង




*គណៈកម្មការទី១០ព្រឹទ្ធសភាពិភាក្សាការងារជាមួយនឹងអាជ្ញាធរខេត្តកំពង់ធំ*

កាលពីថ្ងៃទី២៥ ដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ នៅខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង គណៈប្រតិភូគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយនៃព្រឹទ្ធសភា (គណៈកម្មការទី១០) ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានអញ្ជើញចុះឈ្វេងយល់ការអនុវត្តច្បាប់ និងការងារតាមវិស័យជាសមត្ថកិច្ចរបស់ខ្លួន ជាពិសេសឈ្វេងយល់អំពីការយល់ដឹង និងការចូលរួមអនុវត្តច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ បញ្ហាប្រឈមនានាក្នុងការអនុវត្តតួនាទី ភារកិច្ច ក្នុងក្របខ័ណ្ឌ នៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងលទ្ធផល នៃការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការអភិវឌ្ឍមូលដ្ឋាន។

ក្នុងឱកាសបំពេញការងារនៅទឹកដីខេត្តកំពង់ធំ គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជួបប្រជុំពិភាក្សាការងារជាមួយនឹងរដ្ឋបាលខេត្តកំពង់ធំ ដឹកនាំដោយឯកឧត្តម **ខូន រតនៈ** អភិបាល នៃគណៈអភិបាលខេត្ត ព្រមទាំងអញ្ជើញទស្សនកិច្ចរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ដើម្បីឈ្វេងយល់អំពីការគ្រប់គ្រង អភិរក្ស ការជួសជុលប្រាសាទនានា ដែលបាននឹងកំពុងតែអនុវត្តដោយអាជ្ញាធរជាតិសំបូរព្រៃគុក និងការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក។

ដោយឡែកនៅខេត្តស្ទឹងត្រែង គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញប្រជុំពិភាក្សាការងារជាមួយនឹងរដ្ឋបាលខេត្តស្ទឹងត្រែងដឹកនាំដោយឯកឧត្តម **ស្វាយ**



*គណៈកម្មការទី១០ព្រឹទ្ធសភាពិភាក្សាការងារជាមួយនឹងអាជ្ញាធរក្រុងស្ទឹងសែន*




គណៈកម្មការទី១០ព្រឹទ្ធសភា ពិភាក្សាការងារជាមួយអាជ្ញាធរខេត្តស្ទឹងត្រែង

**សំអ៊ែង** អភិបាល នៃគណៈអភិបាលខេត្ត ព្រមទាំងអញ្ជើញជួបប្រជុំជាមួយនឹងរដ្ឋបាលក្រុងស្ទឹងសែន ដឹកនាំដោយលោក **ម៉ាត់ ប៊ុនហុង** អភិបាល នៃគណៈអភិបាលក្រុងស្ទឹងសែន និងរដ្ឋបាលក្រុងស្ទឹងត្រែងដឹកនាំដោយលោក **សាយ កុសល** អភិបាល នៃគណៈអភិបាលក្រុងស្ទឹងត្រែង ដើម្បីស្វែងយល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា នៃការអនុវត្តច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ លទ្ធផលនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន។

តាមរយៈសេចក្ដីរាយការណ៍របស់អាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធក្នុងជំនួបនៅខេត្តទាំងពីរ ឯកឧត្តម **ម៉ម ប៊ុននាង** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះរដ្ឋបាលខេត្តទាំងពីរ ដែលបានបំពេញតួនាទីដឹកនាំ សម្របសម្រួលកិច្ចដំណើរការការងារទូទៅ សម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ ជាពិសេសការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ។

ឯកឧត្តម **ម៉ម ប៊ុននាង** បានផ្ដល់អនុសាសន៍ឱ្យថ្នាក់ដឹកនាំខេត្ត ក៏ដូចជាមន្ទីរពាក់ព័ន្ធ កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទ ត្រូវចាត់វិធានការឱ្យបានម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការរំលោភអំណាច ជាពិសេសការចូលរួមទប់ស្កាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀនឱ្យបានកាន់តែប្រសើរឡើងថែមទៀត។ ដោយឡែកចំពោះបញ្ហាប្រឈម និងសំណូមពរនានា ដែលអាជ្ញាធរខេត្តពុំអាចដោះស្រាយបាន គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភានឹងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់វិធានការដោះស្រាយឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា៕

(អត្ថបទ និងរូបភាព៖ នុត សច្ចៈ)



គណៈកម្មការទី១០ព្រឹទ្ធសភាពិភាក្សាការងារជាមួយនឹងអាជ្ញាធរក្រុងស្ទឹងត្រែង

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ សំណេះសំណាលក្រុមប្រឹក្សាឃុំ នៃស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង និងស្រុកកូនមុំ ខេត្តរតនគិរី






*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ នៅស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង*

កាលពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ (ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី) ដឹកនាំដោយឯកឧត្តម **យ៉ង់ សែម** ប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុក ឃុំ នៃស្រុកថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង និងស្រុកកូនមុំ ខេត្តរតនគិរី ដើម្បីឈ្វេងយល់អំពី បញ្ហាប្រឈម និងសំណូមពរនានារបស់អាជ្ញាធរមូលដ្ឋាន ដែលកំពុងជួបប្រទះក្នុងការអនុវត្តការងារកន្លងទៅ។ ការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ការប្រកបរបរអាជីវកម្មរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ផែនការសកម្មភាពរបស់ឃុំ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និងការទប់ស្កាត់ជំងឺកូវីដ-១៩។

ក្នុងឱកាសចុះបេសកកម្មនៅខេត្តស្ទឹងត្រែង នាព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានអញ្ជើញចូលថ្វាយបង្គំព្រះសង្ឃ ព្រមទាំងនាំយកនូវទេយ្យទាន ប្រគេនដល់ព្រះសង្ឃនៅវត្តឧទិស្សារាម ស្ថិតក្នុងស្រុកថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង។ បន្ទាប់មកនៅព្រឹកថ្ងៃដដែល ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដឹកនាំដោយឯកឧត្តម **យ៉ង់ សែម** ប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុក ឃុំ នៅស្រុកថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង។

នារសៀលថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានអញ្ជើញទស្សនកិច្ចរមណីយដ្ឋានបឹងយក្សឡោម ដើម្បីឈ្វេងយល់អំពីការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍវិស័យទេសចរណ៍ នៅក្នុងតំបន់រមណីយដ្ឋានបឹងយក្សឡោម ខេត្តរតនគីរី និងបានអញ្ជើញគោរពវិញ្ញាណក្ខន្ធឯកឧត្តមនាយឧត្តមសេនីយ៍ព្រឹទ្ធាចារ្យ **ម៉ូ ថន** អតីតសមាជិកព្រឹទ្ធសភា និងឯកឧត្តមនាយឧត្តមសេនីយ៍ព្រឹទ្ធាចារ្យ **ស៊ើយ កែវ** អតីតសមាជិកព្រឹទ្ធសភា ព្រមទាំងអញ្ជើញសួរសុខទុក្ខឯកឧត្តម **ម៉ូ ឡាំ** តំណាងរាស្ត្រខេត្តរតនគិរី ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ស្ថិតក្នុងក្រុងបានលុង នៅខេត្តរតនគិរី។

ក្នុងដំណើរបំពេញបេសកកម្មនៅខេត្តរតនគិរី នៅព្រឹកថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានអញ្ជើញចូលថ្វាយបង្គំព្រះសង្ឃ ព្រមទាំងនាំយកនូវទេយ្យទានប្រគេនដល់ព្រះសង្ឃនៅវត្តគិរីសោភណ្ឌ ស្ថិតក្នុងវត្តគិរីសោភណ្ឌ ស្រុកកូនមុំ ខេត្តរតនគិរី។ បន្ទាប់មកនៅព្រឹកថ្ងៃដដែលនោះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដឹកនាំដោយឯកឧត្តម **យ៉ង់ សែម** ប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងសមាជិក សមាជិកាក្រុមប្រឹក្សាស្រុក ឃុំ នៃស្រុកកូនមុំ ខេត្តរតនគិរី។

ក្នុងឱកាសជួបសំណេះសំណាលនៅស្រុកថាឡាបរីវ៉ាត់ និងស្រុកកូនមុំ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមភាគទី៨ បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំបំពេញភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរ ព្រមទាំងបានផ្តល់អនុសាសន៍ដល់អាជ្ញាធរត្រូវតែផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើងថែមទៀត និងព្យាយាមដោះស្រាយរាល់បញ្ហាប្រឈម ការលំបាក ការខ្វះខាតរបស់





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ នៅស្រុកកូនមុំ ខេត្តរតនគិរី*

មូលដ្ឋានឱ្យបានឆាប់រហ័ស ប្រកបដោយតម្លាភាព និង យុត្តិធម៌។

ក្នុងឱកាសនោះ ឯកឧត្តម **យ៉ង់ សែម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ក៏បានពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនដល់អាជ្ញាធស្រុកទាំងពីរ។ ឯកឧត្តមបានអំពាវនាវដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ចូលរួមបំផុសចលនាដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យទៅចូលរួមចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ព្រមទាំងត្រូវបន្តយកចិត្តទុកដាក់ខ្ពស់ចំពោះជំងឺកូវីដ-១៩ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការរបស់រាជរដ្ឋាភិបាល គឺ ៣កុំ និង៣ការពារ។ ឯកឧត្តមបានក្រើនរំលឹកដល់អាជ្ញាធរទាំងអស់ជួយចូលរួមបំផុសចលនាដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ត្រូវថែរក្សាឯកសារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងឯកសារសម្គាល់អត្តសញ្ញាណកម្មសម្រាប់បម្រើឱ្យការបោះឆ្នោត ឯកសារអត្រានុកូលដ្ឋាន អប់រំកូនចៅឱ្យខិតខំរៀនសូត្រ រស់នៅឱ្យឆ្ងាយពីគ្រឿងញៀន ចិញ្ចឹមសត្វ និងដាំដំណាំរួមផ្សំផ្សេងៗ ដើម្បីបង្កើនប្រាក់ចំណូលបន្ថែមទៀត។

ឯកឧត្តម **យ៉ង់ សែម** បានមានប្រសាសន៍បន្តថា សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រធានភូមិ ដែលជាអ្នកបម្រើជួរមុខនៅមូលដ្ឋានត្រូវខិតខំបង្កើនសមត្ថភាព មានអាកប្បកិរិយាថ្លៃថ្នូរ ស្អាតស្អំ គោរពច្បាប់ មិនរើសអើង ខិតខំរិះរកការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ ធ្វើយ៉ាងណាឱ្យទទួលបានការគោរពស្រឡាញ់ និងជំនឿទុកចិត្តពីប្រជាពលរដ្ឋ។

ឯកឧត្តមបានផ្ដាំផ្ញើដល់លោកមេឃុំ ជំទប់ទី១ ជំទប់ទី២ ខិតខំរួមសហការគ្នាជំរុញដោះស្រាយនូវបញ្ហាប្រឈម សំណូមពរនានា ដែលនៅសេសសល់ឱ្យបានទាន់ពេលវេលា ហើយបញ្ហាណាដែលហួសពីដែនសមត្ថកិច្ចនោះ សូមលើកស្នើតាមឋានានុក្រម ទៅសមត្ថកិច្ចស្រុក ក្រុង ខេត្ត ដើម្បីជួយរកដំណោះស្រាយ។

(អត្ថបទ និងរូបភាព៖ គឹម សិទ្ធី)



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ អញ្ជើញគោរពវិញ្ញាណក្ខន្ធ ឯកឧត្តមនាយឧត្តមសេនីយ៍ព្រឹទ្ធាចារ្យ ប៊ូ ថង*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ អញ្ជើញគោរពវិញ្ញាណក្ខន្ធ ឯកឧត្តម នាយឧត្តមសេនីយ៍ព្រឹទ្ធាចារ្យ សៀង កែវ*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ សំណេះសំណាលក្រុមប្រឹក្សាសង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រធានភូមិ នៅក្រុងក្រចេះ



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ សំណេះសំណាលក្រុមប្រឹក្សាសង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រធានភូមិ នៅខេត្តក្រចេះ*

នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដឹកនាំដោយឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងជាប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រធានភូមិ នៅក្រុងក្រចេះ ខេត្តក្រចេះ ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តការងារ និងបញ្ហាប្រឈមនានារបស់ក្រុមប្រឹក្សាសង្កាត់។

បន្ទាប់ពីស្តាប់សេចក្តីរាយការណ៍របស់លោកអភិបាលក្រុងរួចមក ឯកឧត្តម **យ៉ង់ សែម** បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនចំពោះសមាជិកក្រុមប្រឹក្សាសង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានភូមិ នៅក្រុងក្រចេះ ខេត្តក្រចេះ។ ឯកឧត្តមប្រធានក៏បានក្រើនរំលឹកដល់ក្រុមប្រឹក្សាឃុំឱ្យត្រៀមខ្លួនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នាពេលខាងមុខ។ ជាមួយគ្នានេះ អាជ្ញាធរពាក់ព័ន្ធ និងក្រុមប្រឹក្សាសង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រធានភូមិ ត្រូវបន្តយកចិត្តទុកដាក់អនុវត្តការងារទៅតាមតួនាទីភារកិច្ចឱ្យកាន់តែសកម្ម យកចិត្តទុកដាក់លើការងាររក្សាការពារសុខសុវត្ថិភាពជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ។

ឯកឧត្តម **យ៉ង់ សែម** បានថ្លែងនូវការកោតសរសើរចំពោះអាជ្ញាធរក្រុង និងក្រុមប្រឹក្សាសង្កាត់ទាំងអស់ ដែលបានខិតខំបំពេញតួនាទី ភារកិច្ចរបស់ខ្លួនបម្រើប្រជាពលរដ្ឋ និងអភិវឌ្ឍមូលដ្ឋាន ព្រមទាំងបានចូលរួមដោះស្រាយរាល់បញ្ហាទុក្ខកង្វល់ និងសំណូមពរនានារបស់បងប្អូនប្រជាពល-



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*



*សមាជិកក្រុមប្រឹក្សាសង្កាត់ឡើងរាយការណ៍*





*ឯកឧត្តម យ៉ង់ សែម ប្រគល់វត្ថុអនុស្សាវរីយ៍ និងថតរូបអនុស្សាវរីយ៍ជាមួយនឹងក្រុមប្រឹក្សាសង្កាត់*

រដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានយ៉ាងល្អ។

ឯកឧត្តមបានជំរុញដល់អាជ្ញាធរ និងប្រជាពលរដ្ឋត្រូវខិតខំអប់រំកូនៗរបស់ខ្លួនឱ្យខិតខំរៀនសូត្រពីព្រោះថា មានតែការសិក្សាទេ ដែលអាចជួយឱ្យប្រទេសជាតិមានការរីកចម្រើនបាន ដូច្នេះយើងត្រូវខិតខំបណ្ដុះបណ្ដាលកូនយៗ ដែលជាទំពាំងស្នងឫស្សី ហើយយើងត្រូវដឹងគុណចំពោះវីរជនទាំងអស់ដែលបានលះបង់គ្រប់បែបយ៉ាង ដើម្បីប្រទេសជាតិ។

ឯកឧត្តម **យ៉ង់ សែម** បានជំរុញ និងលើកទឹកចិត្តដល់អាជ្ញាធរ និងក្រុមប្រឹក្សាឃុំទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ជាមួយនឹងប្រជាពលរដ្ឋដែលខ្លួនគ្រប់គ្រង ហើយជំរុញពួកគាត់ឱ្យបានទៅចុះឈ្មោះបោះឆ្នោត និងពិនិត្យមើលឈ្មោះក្នុងបញ្ជីបោះឆ្នោត ព្រមទាំងជំរុញអ្នកដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត ឬទើបគ្រប់អាយុឱ្យទៅចុះឈ្មោះបោះឆ្នោត ដើម្បីត្រៀមលក្ខណសម្បត្តិឱ្យបានគ្រប់គ្រាន់សម្រាប់ទៅបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០២៣ ដើម្បីជ្រើសរើសនូវថ្នាក់ដឹកនាំដ៏ល្អសម្រាប់អភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនបន្ថែមទៀត។

ក្រៅពីជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរក្រុងក្រចេះក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានអញ្ជើញថ្វាយបង្គំព្រះសង្ឃ និងនាំយកនូវទេយ្យវត្ថុ ដែលរួមមាន៖ស្លាដក់ អង្ករ៥០គីឡូក្រាម ត្រីខ២យួរ ទឹកត្រី២យួរ ទឹកស៊ីអ៊ីវ២យួរ មី២កេស ទឹកផ្លែឈើ២កេស ទឹកបរិសុទ្ធ២កេស និងបច្ច័យមួយចំនួនប្រគេនដល់ព្រះសង្ឃ ព្រមទាំងចែកអំណោយដល់ប្រជាពលរដ្ឋក្រីក្រចំនួន៥គ្រួសារ នៅវត្តវេឡុគង្គារាមហៅវត្តអូរឫស្សី ដែលស្ថិតក្នុងក្រុងក្រចេះ ខេត្តក្រចេះ៕

(អត្ថបទ រូបភាព៖ ធុន គីមជី)





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ នាំយកនូវទេយ្យវត្ថុប្រគេនដល់ព្រះសង្ឃ នៅវត្តវេឡុគង្គារាមហៅវត្តអូរឫស្សី និងប្រជាពលរដ្ឋក្រីក្រ ខេត្តក្រចេះ*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❈ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញដឹកនាំ៖

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១ព្រឹទ្ធសភា ដើម្បីត្រៀមរៀបចំពិធីសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្តីពីការងារបោះឆ្នោតនៅក្រុងខេមរភូមិន្ទ ខេត្តកោះកុង នាថ្ងៃទី៤ ដល់ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។

-កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ស្តីពីការត្រៀមរៀបចំពិធីសំណេះណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ ក្នុងក្រុងក្រចេះ ខេត្តក្រចេះ នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១ព្រឹទ្ធសភា ដើម្បីត្រៀមរៀបចំពិធីសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្តីពីការងារបោះឆ្នោតនៅក្រុងក្រចេះ ខេត្តក្រចេះ នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។

❈ឯកឧត្តម **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី២ព្រឹទ្ធសភា ស្តីពីការត្រៀមចុះបេសកកម្មរបស់គណៈកម្មការនៅចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ និងបញ្ហាផ្សេងៗ នាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា។

-កិច្ចប្រជុំណែនាំមន្ត្រី នៃលេខាធិការដ្ឋានអមគណៈកម្មការទី២ព្រឹទ្ធសភា និងលេខាធិការដ្ឋានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ដើម្បីត្រួតពិនិត្យការងារ និងត្រៀមលក្ខណសម្បត្តិចុះបេសកកម្មរបស់គណៈកម្មការ នៅ



ចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ និងការពិនិត្យឯកសារសេចក្តីពន្យល់អំពីក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា។



-ចូលរួមកិច្ចប្រជុំក្រុមទទួលបន្ទុកការសើរើលក្ខន្តិកៈ នៃសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិត នារាត្រីថ្ងៃទី១២ និងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា ផ្សាយចេញពីខេត្តកេបិច ប្រទេសកាណាដា ក្នុងគោលបំណងរកដំណោះស្រាយរួមគ្នាមួយ ដើម្បីយកសេចក្តីសម្រេច នៃការសើរើលក្ខន្តិកៈ APF ឆ្លងមហាសន្និបាត APF ដែលប្រព្រឹត្តទៅនាខែកក្កដា ឆ្នាំ២០២២។

❈ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖



-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៤ព្រឹទ្ធសភា ដើម្បីពិនិត្យ

សិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា។



-ចូលរួមកិច្ចប្រជុំជាមួយនឹងគណៈកម្មការនយោបាយ នៃសភាប្រេីភាសាបារាំង តាមប្រព័ន្ធនិម្មិត ផ្សាយចេញពីទីក្រុងកេបិច ប្រទេសកាណាដា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នាថ្ងៃទី១៤ និងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២។



-ដឹកនាំកិច្ចប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **អង្គ វង្ស វឌ្ឍានា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា។

-ដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ



នស/រកម០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ និងសេចក្តីព្រាងច្បាប់ស្តីពី សុវត្ថិភាពម្ហូបអាហារ នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា។

❈លោកជំទាវ **ទី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញដឹកនាំ៖



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១-របាយការណ៍ចុះបេសកកម្មនៅខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត កាលពីថ្ងៃទី២ ដល់ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២។

២-វីដេអូសកម្មភាពចុះសិក្សាឈ្វេងយល់អំពីសិប្បកម្មតម្បាញហូលផាមួង ក្រមា កញ្ជើ ល្ពី និងសម្ភារប្រើប្រាស់កែច្នៃដោយដៃ នៅខេត្តពោធិ៍សាត់ និងខេត្តកំពង់ធំ ព្រមទាំងដំណើរចុះបេសកកម្មនៅខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត។

៣-ការបូកសរុបថវិកាចំណូល-ចំណាយប្រចាំខែមីនា និងខែមេសា ឆ្នាំ២០២២។

៤-បញ្ហាផ្សេងៗ។

-កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា(ក្រុមទី៣) នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ



ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨

**២**-សេចក្តីព្រាងច្បាប់ស្តីពី សុវត្ថិភាពម្ហូបអាហារ។



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា នាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

**១**-សេចក្តីរាយការណ៍របស់សមាជិកា សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា ស្តីពីសកម្មភាពការងារនៅមូលដ្ឋាន ដើម្បីត្រៀមរៀបចំដំណើរការឆ្ពោះទៅកាន់ការបោះឆ្នោតក្រុម-ប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ខាងមុខ។

**២**-សេចក្តីរាយការណ៍របស់លោកជំទាវប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ស្តីពីក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជាជាមួយនឹងសភា នៃសាធារណរដ្ឋបារាំង កាលពីថ្ងៃទី៦ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២។

**៣**-សេចក្តីរាយការណ៍សមាជិកា សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា ស្តីពីផែនការសកម្មភាពគ្រោងនឹងចុះទៅមូល-ដ្ឋាននៅពេលយុទ្ធនាការឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់។

**៤**-បញ្ហាផ្សេងៗ។

❋ឯកឧត្តម **ម៉ុម ងីមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបាន៖

-អនុញ្ញាតឱ្យ ឯកឧត្តម **លីម ម៉ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ អំពីការត្រៀមរៀបចំកម្មវិធីទទួលដំណើរទស្សនកិច្ចរបស់ក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា ។



-ដឹកនាំកិច្ចប្រជុំពិនិត្យឯកសារ និងពិភាក្សាការងារ ដើម្បីត្រៀមទទួលគណៈប្រតិភូក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា នាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំអគារក្រហមវិមានព្រឹទ្ធសភា។



-ដឹកនាំកិច្ចប្រជុំក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជាជាមួយសភានៃសាធារណរដ្ឋបារាំង ដើម្បីពិនិត្យឯកសារ និងផ្ទៀងផ្ទាត់កម្មវិធីការងារសម្រាប់ទទួលគណៈប្រតិភូក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា ដែលនឹងអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី៦ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២។

-អនុញ្ញាតឱ្យមន្ត្រីក្រុមការងាររាជបណ្ឌិត្យសភាកម្ពុជា ចូលជួបសម្តែងការគួរសម និងសម្ភាសន៍ ដើម្បីរៀបចំធ្វើគុណកថា នាថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។

-អញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ដើម្បីពិនិត្យ និងពិភាក្សាអំពីផែនការសកម្មភាពការងាររបស់គណៈកម្មការ នៅចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩



ព្រឹទ្ធសភា នីតិកាលទី៤ នាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។

❈ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញដឹកនាំៈ

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី សុវត្ថិភាពម្ហូបអាហារ នារសៀលថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈ-កម្មការទី៩ព្រឹទ្ធសភា។

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាជាលើកចុងក្រោយលើសេចក្ដីព្រាងច្បាប់ស្ដីពី សុវត្ថិ-ភាពម្ហូបអាហារ នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំពិសេសព្រឹទ្ធសភា។



-កិច្ចប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី សុវត្ថិភាពម្ហូបអាហារ នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំពិសេសព្រឹទ្ធសភា ។



❈នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យលើរបាយការណ៍ស្ដីពី សកម្មភាពលទ្ធផលការងារ និងរបាយ-ការណ៍ថវិការបស់គណៈកម្មការប្រចាំខែឧសភា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។



❈នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យលើឯកសារត្រៀម ដើម្បីជួបផ្ដល់កិច្ចសម្ភាសន៍ជូនសារព័ត៌មានវីអូឌី (VOD) នៃមជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វ-ផ្សាយឯករាជ្យ នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។

## ការទទួលពាក្យបណ្ដឹង

❈នៅខែឧសភា ឆ្នាំ២០២២ ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន៩ករណី បញ្ជូនពាក្យបណ្ដឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន២ករណី កំពុងពិនិត្យសិក្សាចំនួន៥ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន៩ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន២ករណី តម្កល់ទុកជាឯកសារចំនួន១ករណី (សម្របសម្រួលដោះស្រាយបញ្ចប់) ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងចម្លងជូនគណៈកម្មការនានារបស់ព្រឹទ្ធសភាចំនួន១៣ករណី៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨




❈នាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ឯកឧត្ដម **ជា ខេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់ និងស្មៀន ស្ដីពីការងារត្រៀមលក្ខណសម្បត្តិក្នុងការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅសាលាសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

❈ឯកឧត្ដមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ និងចុះពិនិត្យមើលក្រុមការងារគ្រឿងចក្រដែលកំពុងសាងសង់ព្រះវិហារគំរូ ពិនិត្យមើលហេដ្ឋារចនាសម្ព័ន្ធសំណង់ទំនប់ទឹក និងផ្លូវនានា ព្រមទាំងដឹកនាំក្រុមការងារចុះពិនិត្យទំនប់ទឹក និងគ្រឿងចក្រដឹកប្រឡាយប្រវែង២.៥០០ម៉ែត្រ ដើម្បីរំដោះជំនន់ទឹកភ្លៀង នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករដែលកំពុងប្រមូលផលផ្លែមង្ឃុត ព្រមទាំងចុះពិនិត្យទំនប់ទឹក និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៦ ខែឧសភាឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងទទួលកូនឈើដែលបញ្ជាទិញសរុបចំនួន១៤.៦៥៥ដើម សម្រាប់ដាំនៅតំបន់អភិវឌ្ឍន៍កសិកម្មកែវផុស និងតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងចុះណែនាំកម្មករអំពីរបៀបថែទាំដំណាំដាំដុះ ព្រមទាំងចុះសួរសុខទុក្ខប្រជាពលរដ្ឋ ដែលអញ្ជើញមកសម្រាកកម្សាន្តនៅតំបន់អភិវឌ្ឍន៍ កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២។

-ដឹកនាំកម្មករ និងប្រជាពលរដ្ឋរស់នៅតំបន់អភិវឌ្ឍន៍ កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ចូលរួមដាំដើមឈើឡើងវិញ រួមមាន៖ នាងនួន បេង និងធ្នង់សរុបចំនួន១៣.២៥០ដើម ដើម្បីចូលរួមការពារបរិស្ថាន ជាមួយនឹងរាជរដ្ឋាភិបាល ព្រមទាំងចុះសួរសុខទុក្ខប្រជាពលរដ្ឋ និងចុះពិនិត្យមើលការងារជីកប្រឡាយរំដោះជំនន់ទឹកភ្លៀង នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលហេដ្ឋារចនាសម្ព័ន្ធនានា និងបង្ហាត់បង្រៀនដល់ពួកគាត់អំពីរបៀបថែទាំដើមឈើ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករ និងដឹកនាំក្រុមការងារកសិកម្មរួមជាមួយនឹងវិស្វករសំណង់ ចុះពិនិត្យ ដាក់ផែនការការងារអភិវឌ្ឍន៍បន្តទៀត ព្រមទាំងសួរសុខទុក្ខក្រុមការងារគ្រឿងចក្រសាងសង់ទំនប់រំដោះជំនន់ទឹកភ្លៀង នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២។

-ចុះពិនិត្យមើលទំនប់ទឹកដែលអាចស្ដុកទឹកបាន៣០០.០០០ម៉ែត្រគូប សម្រាប់បំពេញសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងណែនាំពួកគាត់អំពីរបៀបតែងមែកស្វាយ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២២។



❋លោកជំទាវ **ទី ប្ញ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ នៅសាលាឃុំជ្រៃលាស់ ខេត្តកណ្ដាល នាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងអតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន អ្នកផ្ទុកHIV កម្លាំងប្រជាការពារ សមាជិកក្រុមប្រឹក្សាឃុំ និងយុវជន នៅឃុំពញាឮ និងព្រែកតាទែន ខេត្តកណ្ដាល ចំនួន១៥៧នាក់ នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២។

❋នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ ម៉ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារថ្នាក់ស្រុកជាមួយនឹងក្រុមប្រឹក្សាឃុំ ស្ដីពី "ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ទាំង៧ចំណុច" នៅស្រុកកំពង់សៀម ស្រុកកងមាស ស្រុកកោះសូទិន ស្រុកចំការលើ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

❋ឯកឧត្តម **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់បឹងធំ និងសង្កាត់ស្នោរ ដើម្បីឈ្វេងយល់ អំពីសភាពការរួមក្នុងមូលដ្ឋាន ការងារសន្តិសុខសណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈ និងការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ព្រមទាំងឧបត្ថម្ភនូវថវិកាមួយចំនួន នៅខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី៤ និងថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់កន្ទោក និងអាជ្ញាធរខណ្ឌកំបូល ខណ្ឌដង្កោ រាជធានីភ្នំពេញ នាថ្ងៃទី២២ និងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២។

❋នាព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ លោកជំទាវ




**មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងសមាជិក សមាជិកាក្រុមប្រឹក្សាស្រុក និងឃុំទាំង១៦ នៅស្រុករមាសហែក ខេត្តស្វាយរៀង ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពនៃការអភិវឌ្ឍក្នុងស្រុក និងឃុំទាំង១៦ ការងារសន្តិសុខសណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈ និងការត្រៀមខ្លួនរបស់ក្រុមប្រឹក្សាឃុំ ក្នុងការចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

❋ឯកឧត្តម **ម៉ម ប៊ុននាន** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល សួរសុខទុក្ខអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋឃុំគោកត្រប់ចំនួន១៦៥នាក់ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅសាសាឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល នាព្រឹកថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នង

ផ្ទះនៅភូមិស្លែង ភូមិតាឡឹក ភូមិព្រៃទទឹង ភូមិដំណាក់ត្របែក និងភូមិត្រពាំងបាគូ ចំនួន២.៨២០នាក់ ព្រមទាំងចុះជួបសំណេះ-សំណាលជាមួយនឹងលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចំនួន ១២៣នាក់ នៅសាលាបឋមសិក្សាត្នួន និងបាននាំយកអំណោយចែកជូនដល់សិស្សានុសិស្ស រួមមាន៖ សៀវភៅ២ក្បាល ប៊ិច៣ដើម ជ័រលុប១ បន្ទាត់១ ស្ករគ្រាប់១កញ្ចប់ និងឧបត្ថម្ភថវិកាមួយចំនួន នៅឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នាព្រឹកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។



-ជួបសំណេះសំណាលការងារជាមួយនឹងក្រុមប្រឹក្សាឃុំត្រពាំងវែង ប្រជាការពារភូមិ ឃុំ ដើម្បីឈ្វេងយល់អំពីការត្រៀមលក្ខណសម្បត្តិក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព និងរបៀប-រៀបរយសាធារណៈជូនប្រជាពលរដ្ឋ ក្នុងរយៈពេល នៃការឃោសនាបោះឆ្នោត និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅសាលាឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលនាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះនៅភូមិក្បាលសេះ ភូមិក្រាំងធ្មៃ ភូមិចារ ភូមិគោកព្រីង ភូមិគោកត្រប់ និងភូមិលៀក ចំនួន២.២៧៤នាក់ ព្រមទាំងជួបសំណេះសំណាលជាមួយនឹងលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចំនួន១២៣នាក់ នៅសាលាបឋមសិក្សាគោកត្រប់មុនស្វ័រ និងបាននាំយកអំណោយមកចែកជូនដល់សិស្សានុសិស្ស រួមមាន៖ សៀវភៅ២ក្បាល ប៊ិច៣ដើម ជ័រលុប១ បន្ទាត់១ ស្ករគ្រាប់១កញ្ចប់ និងឧបត្ថម្ភថវិកាមួយចំនួន នៅឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នារសៀលថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋមកពីឃុំអន្លង់រមៀត ឃុំថ្មី និងឃុំត្រពាំងវែង សរុបចំនួន១.៤៣៤នាក់ នៅឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នាព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២។



-ជួបសំណេះសំណាលការងារជាមួយនឹងក្រុមប្រឹក្សាឃុំគោក-ត្រប់ ប្រជាការពារភូមិ ឃុំ ដើម្បីឈ្វេងយល់អំពីការត្រៀមលក្ខណ-សម្បត្តិក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព និងរបៀបរៀបរយសាធារណៈជូនប្រជាពលរដ្ឋ ក្នុងរយៈពេលនៃការឃោសនាបោះឆ្នោត និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅសាលាឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នារសៀលថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២។




❋នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភា លោកជំទាវ **ឆន សៅរ៍ធន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ

ចូលរួមក្នុងពិធីសម្ពោធជាផ្លូវការរោងចក្រផលិតចំណីអាហារ និងពិធីចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នារវាងសកលវិទ្យាល័យជាស៊ីម កំចាយមារ និងក្រុមហ៊ុនស៊ីភី ខេមបូឌា ចំកាត់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅរោង-ចក្រ ស៊ី ភី ស្ថិតនៅភូមិឈើទាល ឃុំជំពូវន្ត ស្រុកជុំគិរី ខេត្តកំពត។




❋នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធ-សភាប្រចាំភូមិភាគទី៥ បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធឆ្លងសាលាធម្មសភា និងសមិទ្ធផលនានាក្នុងវត្តចែង ក្រោមអធិបតីភាពឯកឧត្តម ឧត្តមសេនីយ៍ឯកបណ្ឌិត **ហ៊ីន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅក្នុងឃុំធ្លក ស្រុកត្រាំកក់ ខេត្តតាកែវ។

❋នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំការងារ នៅសាលាឃុំឫស្សីស្រុក ស្រុកពាមជរ។

❋នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា ១ខ្នង កម្ពស់២ជាន់ មាន១២បន្ទប់ នៅវិទ្យាល័យរុក្ខគិរី ព្រមទាំងជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុករុក្ខគិរី ខេត្តបាត់ដំបង។

❋ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាអធិបតីភាពក្នុងយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ និងជំងឺទូទៅដល់ប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ដើម្បីជាការលើកទឹកចិត្តដល់គ្រូពេទ្យទាំងអស់ ឱ្យខិតខំធ្វើការបម្រើសេវាសុខភាពសាធារណៈជូនប្រជាជននៅតាមសហគមន៍ នៅក្នុងឃុំព្រែកតានង់ ស្រុកកោះ-សូទិន ខេត្តកំពង់ចាម នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២២។

-នាំយកថវិកាចូលរួមកាកបាទក្រហមកម្ពុជា ជូនសាខាកាក-បាទក្រហមកម្ពុជាប្រចាំខេត្តត្បូងឃ្មុំ និងសាខាកាកបាទក្រហមកម្ពុជាប្រចាំខេត្តកំពង់ចាម នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។



❋នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់នូវសមិទ្ធផលនានាក្នុងវិទ្យាល័យសម្តេច **ហេង សំរិន** អន្លង់ជ្រៃ និងផ្តួចផ្តើមកសាង ជួសជុលរៀបចំហេដ្ឋារចនាសម្ព័ន្ធថ្មី នៃវិទ្យា-ល័យអន្លង់ជ្រៃ រួមមាន៖ ១-កសាងអគារសិក្សាថ្មីចំនួន១ខ្នង កម្ពស់២ជាន់ ស្មើនឹង១២បន្ទប់ ២-កសាងផ្លូវបេតុងជុំវិញក្នុងបរិវេណសាលា តារាងបាល់បោះ របង ខ្លោងទ្វារថ្មី ទី៣-ជួសជុលកែលម្អអគារសិក្សាចាស់ចំនួន៦ខ្នង និងរៀបចំសួនច្បារថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន**

ប្រធានរដ្ឋសភា និងសម្តេចធម្មវិសុទ្ធវង្សា **សៅ ទី** នៅភូមិអន្លង់-ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។



❈នាថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២២ ក្រុមសមាជិកព្រឹទ្ធ-សភាប្រចាំភូមិភាគទី២ ដឹកនាំដោយឯកឧត្តម **ឈិត គឹមយាត** អនុប្រធានក្រុម និងជាអនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធសពសម្តេចឧត្តមទេពញាណ **ហ៊ុន ណេង** ប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ នៃរដ្ឋសភា និងជាតំណាងរាស្ត្រខេត្តកំពង់ចាម នៅគេហដ្ឋានភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

❈នាថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះ-សំណាល និងពិភាក្សាការងារនៅខេត្តកោះកុង ក្រុងខេមរភូមិន្ទ និងសង្កាត់ស្មាច់មានជ័យ សង្កាត់ដងទង់ និងសង្កាត់ស្ទឹងវែង ព្រមទាំងផ្តល់ជូនថវិកាមួយចំនួនដល់សង្កាត់ទាំងបី។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមប្រជុំជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទាំង១០ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍ស្តីពី លទ្ធ-ផលការងារ ខែមេសា និងទិសដៅការងារ ខែឧសភា ឆ្នាំ២០២២ បន្តពង្រឹងការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការងារផ្តល់-សេវាជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ នាថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។



-ចូលរួមប្រជុំជាមួយនឹងលោកមេភូមិទាំង១៣ និងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍ សំណូមពរ និងដំណោះស្រាយជូនប្រជាពលរដ្ឋលើការងារការពារសន្តិសុខសណ្តាប់ធ្នាប់ សេវាដឹកជញ្ជូនសំរាម ការងារអគ្គិសនីបំភ្លឺផ្លូវ ការងារចុះតាមខ្នងផ្ទះ និងជំរុញការងារចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភនូវថវិកាមួយចំនួន នាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២។



-ចូលរួមជាមួយនឹងក្រុមប្រឹក្សាសង្កាត់ផ្សារដើមគ និងសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីពិនិត្យវិធីផ្តល់សេវាពិនិត្យ ព្យាបាលជំងឺទូទៅ និងព្យាបាលភ្នែក ដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋចំនួន២សង្កាត់ នៅបរិវេណវត្តនាគវ័ន្ត នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខ លោក **ផុន សារ៉ែន** សមាជិកក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ព្រមទាំងឧបត្ថម្ភអង្ករ កន្សែងពោះគោ សាប៊ូ និងថវិកាមួយចំនួន នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២។



-ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធសព ឧកញ៉ា **ឫទ្ធី សំណាង** នៅគេហដ្ឋានលេខ១១ ផ្លូវលេខ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជ-ធានីភ្នំពេញ នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២។



-ចូលរួមប្រជុំជាមួយនឹងប្រធានភូមិទាំង១៣ ក្រុមប្រឹក្សា និងគណៈបញ្ជាការឯកភាពសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីពង្រឹងការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋ ដែលត្រូវទៅចូលរួមបើកយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ នាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២។

❋ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងក្រុមគ្រូពេទ្យ ក្រុមការងារចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ (ដូសជំរុញ) នៃទីចាត់ការបំភ័ន្ត-អក្ខរៈ នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ និងពិនិត្យមើលស្ថានភាពបងប្អូនប្រជាពលរដ្ឋដែលមកទទួលការចាក់វ៉ាក់-សាំងការពារជំងឺកូវីដ-១៩ (ដូសជំរុញ ) នៅក្នុងវត្តដំណាក់អំពិល ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល នាព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។



-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខន** អនុប្រធានទី២ព្រឹទ្ធសភា ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនដល់បងប្អូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅក្នុងវត្តដំណាក់អំពិល ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល នាព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងសួរសុខទុក្ខសមាជិក សមាជិកាក្រុមប្រឹក្សាឃុំដំណាក់អំពិល សរុបចំនួន៩០នាក់ នៅស្រុកអង្គ-ស្នួល ខេត្តកណ្តាល នាព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២។



-ជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ អាជ្ញាធរ និងសមាជិកក្រុមប្រឹក្សាឃុំដំណាក់អំពិល ក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល សរុបចំនួន៣៥៥នាក់ នាព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២។

❋ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីក្នុងកម្មវិធីជួបសំណេះសំណាលជាមួយនឹងក្រុម

ប្រឹក្សាឃុំ ស្រុក និងគណៈអភិបាលស្រុក ព្រមទាំងឧបត្ថម្ភថវិកា និងសម្ភារជូនគ្រួសារ នៃសព១គ្រួសារ នៅស្រុករមាសហែក ខេត្តស្វាយរៀង នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។

-ជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភថវិកា សម្ភារជូនចាស់ជរា និងសួរសុខទុក្ខគ្រួសារ នៃសព២គ្រួសារ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភថវិកា សម្ភារ និងសួរសុខទុក្ខគ្រួសារ នៃសព៤គ្រួសារ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២។

-ជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២។

❈ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ មន្ត្រីភូមិ និងមន្ត្រីរាជការចូលនិវត្តន៍នៅឃុំខ្ទុំក្រាំង ឃុំទំព័រមាស ឃុំតាំងក្រូច និងស្រុកសំពោងទង ដើម្បីឈ្វេងយល់ អំពីការត្រៀមរៀបចំការបោះឆ្នោតឃុំ សង្កាត់ នាពេលខាងមុខ ព្រមទាំងឧបត្ថម្ភជូនសមាជិកនៃអង្គពិធី រួមមាន៖ ក្រមា១ សាប៊ូ២ដុំ ប៊ីចេង១កញ្ចប់ នៅស្រុកសំពោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៣០ ខែមេសា និងថ្ងៃទី៦ ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីចម្រើនអាយុវឌ្ឍនមង្គល ព្រះមុនីសត្ថាចារ្យកោសល **កែវ ចន្ថា** ព្រះរាជាគណៈថ្នាក់កិត្តិយស ទីប្រឹក្សាផ្ទាល់ សម្តេចព្រះមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះមេគណខេត្តកំពង់ស្ពឺ ព្រមទាំងប្រគេនបច្ច័យមួយចំនួននៅវត្តដំណាក់ត្រាច ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២។




-ចុះសួរសុខទុក្ខលោក **ម៉ែន ឡឿន** អតីតប្រធានក្រុមប្រឹក្សាស្រុកគងពិសី ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន និងឧបត្ថម្ភសម្ភារមួយចំនួនរួមមាន៖ ទឹកបរិសុទ្ធ២កេស មីចំនួន៤កេស ត្រីខ២យួរ ទឹកផ្លែឈើ១ដប ទឹកដោះគោឆៅ២យួរ នំប៉័ង១០ដើម និងថវិកាមួយចំនួន នៅឃុំពោធិ៍ចំរើន ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២។

❈នាថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ឈាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបញ្ចុះបឋមសិលា និងបើកការដ្ឋានសាងសង់ស្តូបអនុស្សាវរីយនយោបាយឈ្នះឈ្នះប៉ៃលិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសង្កាត់អូតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន។

❈ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពលោក **ឈុន សារេត** អតីតស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ នៅគេហដ្ឋាននៃសពឋិតនៅភូមិពីរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងប្រជាជនភូមិត្រពាំងអំពិល ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ និងឧបត្ថម្ភសារុង១ និងថវិកាមួយចំនួន នាព្រឹកថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២២។

❈ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធី៖

-សម្ពោធមហាកុដិ និងសមិទ្ធផលនានាក្នុងវត្តវេឡុវនោទ្យាន



(ហៅវត្តស្វាយចេក) ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២។



-សម្ពោធមជ្ឈមណ្ឌលអប់រំអង្គការកុមារមេគង្គ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅភូមិបន្ទាយឆ្មារលិច ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២។



-សម្ពោធអគារសិក្សា និងសមិទ្ធផលនានាក្នុងស្រុកមង្គលបូរី ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២។

-បើកការដ្ឋានកសាងផ្លូវបេតុងចំនួន៥ខ្សែ ប្រវែងជាង២.០៥០



ម៉ែត្រ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២។



-ប្រគល់-ទទួលថវិកាពីសប្បុរជនក្នុងឱកាសខួបលើកទី១៥៩ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ វាត្រា** ប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជា នៅសាខាកាកបាទក្រហមកម្ពុជា ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២២។



-សម្ពោធសាលាធម្មសភា វត្តជលធារាសម្បត្តិ (ជប់វារី) ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២។

-សម្ពោធឆ្លងគរុនិវេសនដ្ឋាន (កុដិគ្រូបង្រៀន) វត្តប្រាសាទ-ស្រះកណ្ដាល ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធ-ប្រឆាំងគ្រឿងញៀន នៅឃុំវាលស្បូវ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២។

❋ឯកឧត្តម **ឆាយ ខណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាគណៈអធិបតីភាពក្នុងពិធីសំណេះសំណាល និងចែកកញ្ចប់អាហារសម្រាប់ស្រាយបួសក្នុងខែរ៉ាម៉ាឌន ជូនដល់បងប្អូនប្រជាពលរដ្ឋនៅស្រុកកងមាស ខេត្តកំពង់ចាម ចំនួន៥៥០គ្រួសារ ព្រមទាំងចែកអំណោយក្នុង១គ្រួសារទទួលបាន៖ អង្ករ២៥គីឡូ-ក្រាម ប្រេងឆា១ដប ទឹកដោះគោ៤កំប៉ុង ទឹកស៊ីអ៊ីវ១យួរ និងទឹកត្រី១យួរ ស្ករ-ស១គីឡូក្រាម និងផ្លែល្មើ១ប្រអប់ នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២២។




-ជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយនឹងបងប្អូនប្រជាពលរដ្ឋសាសនិកខ្មែរឥស្លាម ព្រមទាំងនាំយកអំណោយជាកញ្ចប់អាហារសម្រាប់ស្រាយបួសជូនបងប្អូនប្រជាពលរដ្ឋចំនួន១០០គ្រួសារ នៅក្នុងឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយនឹងបងប្អូនប្រជាពលរដ្ឋសាសនិកខ្មែរឥស្លាម ព្រមទាំងនាំយកអំណោយ



អំពូលផ្ទាំងសូឡាចំនួន៦០ផ្ទាំង ដើម្បីចែកជូនសម្រាប់ប្រើប្រាស់បំភ្លឺតាមវិហារខ្មែរឥស្លាមចំនួន១៣កន្លែង និងស៊ូរ៉ាវចំនួន៨ នៅស្រុកសន្ទុក ខេត្តកំពង់ធំ នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២។



-ជួបសំណេះសំណាល សួរសុខទុក្ខ និងចែកកញ្ចប់អាហារសម្រាប់ស្រាយបួសក្នុងខែរ៉ាម៉ាឌននៅពេលខាងមុខ ដោយមានប្រជាពលរដ្ឋជាសាសនិកខ្មែរឥស្លាមចូលរួមចំនួន១០០គ្រួសារ ព្រមទាំងចែកអំណោយ រួមមាន៖ អង្ករចំនួន៥០គីឡូក្រាម ប្រេងឆា១ដប ទឹកដោះគោចំនួន៤កំប៉ុង ទឹកស៊ីអ៊ីវ និងទឹកត្រីចំនួន១យួរ ស្ករ-ស១គីឡូក្រាម ទឹកក្រូចចំណុះ៣លីត្រចំនួន១ដប និងផ្លែល្មើចំនួន១ប្រអប់ នៅក្នុងសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២។

-នាំយកថវិកាចូលរួមកាកបាទក្រហមកម្ពុជា ជូនសាខាកាកបាទក្រហមកម្ពុជាប្រចាំខេត្តត្បូងឃ្មុំ និងសាខាកាកបាទក្រហមកម្ពុជាប្រចាំខេត្តកំពង់ចាម នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងពិធីបិទព្រឹត្តិការណ៍ប្រកួតបាល់ទាត់

ដណ្ដើមពានរង្វាន់យុវជនដើម្បីការពារសន្តិភាពជុំវគ្គកាលទី១ ឆ្នាំ២០២២ នៅកីឡដ្ឋានភូមិទ្រា៥ ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២។

❋ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកថវិការបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិទី៦ ជូនក្រុមគ្រួសារសពជំទប់ទី១ ឃុំចន្ត្រី ស្រុករមាសហែក និងគ្រួសារសពជំទប់ទី២ ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀងនាថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាខេត្ត ក្នុងពិធីបុណ្យវិសាខបូជា និងបាននាំបច្ច័យទេយ្យទានប្រគេនព្រះសង្ឃក្នុងខេត្តស្វាយរៀង នាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២។

❋ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ប្រគល់សារុង និងសម្ភារមួយចំនួនជូនលោក **លឿង សុភក្ដិ** អភិបាល នៃគណៈអភិបាលស្រុកស្វាយចេក ដើម្បីយកប្រើប្រាស់ និងចែកជូនប្រជាពលរដ្ឋ ដែលជួបការលំបាកជាក់ស្តែង នៅគេហដ្ឋានរបស់ឯកឧត្តម ស្ថិតក្នុងភូមិចក សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២។



-ចូលរួមពិធីសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ក្នុងស្រុកអូរជ្រៅ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ព្រមទាំងនាំយកអំណោយ និងថវិកាមួយចំនួនជូននគរបាល កងរាជអាវុធហត្ថ ប្រតិបត្តិការសឹករង ក្រុមគ្រូពេទ្យ យុវជន ស.ស.យ.ក. ក្រុមការងារអភិវឌ្ឍយុវជន ក្រុមការងារយុវជនខេត្តបន្ទាយមានជ័យ ប្រចាំរាជធានីភ្នំពេញ ប្រជាពលរដ្ឋ និងប្រគេនដែក៥តោន ស៊ីម៉ងត៍២០តោន វត្តចាន់ស៊ីសាមគ្គីរតនារាម ស្ថិតនៅភូមិកូបកើត ឃុំកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២។



-ចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធផលនានា ឃុំអូរសំព័រ ឃុំតាគង់ និងឃុំទួលពង្រ ក្នុងស្រុកម៉ាឡៃ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ព្រមទាំងនាំយកអំណោយ និងថវិកាមួយចំនួនជូននគរបាល កងរាជអាវុធហត្ថ ប្រតិបត្តិការសឹករង ក្រុមគ្រូពេទ្យ ប្រជាការពារ យុវជន ស.ស.យ.ក. ក្រុមការងារអភិវឌ្ឍយុវជន និងប្រជាពលរដ្ឋ ស្ថិតនៅឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្នាក់ការរដ្ឋបាលក្រុងសិរីសោភ័ណ ក្រោមអធិបតីភាពឯកឧត្តមនាយ

ឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្ថិតនៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២។



-ចូលរួមពិធីសម្ពោធសមិទ្ធផលអគារសិក្សា ជាផ្លូវការ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្ថិតនៅសាលាបឋមសិក្សាអូរឫស្សីក្រោម ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងស្រុកថ្មពួក ចំនួន១.៦០០នាក់ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ស្ថិតនៅផ្សារថ្មី ឃុំគំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២។

❋លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីសំណេះសំណាលជាមួយនឹងសមាជិកាក្រុមប្រឹក្សាខណ្ឌ សង្កាត់ គណៈអភិបាលខណ្ឌ និងសកម្មជននារីក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅខណ្ឌឫស្សីកែវ ខណ្ឌច្បារអំពៅ ខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ នាថ្ងៃទី២៣-២៤ ខែមេសា និងថ្ងៃទី២ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២។

-ជាអធិបតីភាពក្នុងពិធីបណ្ដុះបណ្ដាលអ្នកសង្កេតការណ៍របស់គណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍រាជធានីភ្នំពេញ ដើម្បីប្រសិទ្ធភាព នៃការចូលរួមសង្កេតមើលដំណើរប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ នាពេលខាងមុខ តាមរយៈប្រព័ន្ធនិម្មិត (Zoom) នាព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយអនុសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខណ្ឌចំការមន និងខណ្ឌបឹងកេងកង នាព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមវេទិកាស្ដីពី ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងយុវជន យុវនារីនារី នៅសាលាសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២។

❋នាថ្ងៃទី២ ថ្ងៃទី១៥ និងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចុះជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅឃុំព្រៃទឹង ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង។

❋ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាកិត្តិយសក្នុងពិធីជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅឃុំរំចេក និងឃុំកំពាន់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលការងារជាមួយនឹងក្រុមប្រឹក្សាឃុំព្រះធាតុ ឃុំអំពិលតាពក ឃុំដំរិល និងស្មៀន ស្ដីពីការងារត្រៀមលក្ខណសម្បត្តិក្នុងការការពារសន្តិសុខ រក្សាសុវត្ថិភាព និងរបៀបរៀបរយសាធារណៈ ក្នុងរយៈពេលនៃការឃោសនាបោះឆ្នោត និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នាពេលខាងមុខ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់ក្រុមប្រឹក្សាឃុំស្ថិតនៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២។

❋នាថ្ងៃទី៧ ដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ថុន ចន់** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋនៅស្រុកមណ្ឌលសីមា និងក្រុមខេមរភូមិន្ទ ក្នុងខេត្តកោះកុង។

❋នាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ខឹម**

**លាវ** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យសពឧបាសិកា **ហ្វុង គីង** បិតាបង្កើតលោកជំទាវ **ខុង ស៊ុនអេង** តំណាងរាស្ត្រមណ្ឌលកំពង់ចាម នៅក្រុងកំពង់ចាម។

❃នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ញ៉ែម សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិនិត្យផែនការនៃយុទ្ធនាការឃោសនាបោះឆ្នោត និងថ្ងៃបោះឆ្នោតក្រុមប្រឹក្សាឃុំ នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

❃ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចំនួន៦០នាក់ ទៅព្យាបាលជំងឺជូនប្រជាពលរដ្ឋ ចំនួន៦០៥នាក់ ព្រមទាំងបានឧបត្ថម្ភដល់អ្នកជំងឺក្នុងម្នាក់ៗទទួលបានក្រមា១ និងឧបត្ថម្ភថវិកាមួយចំនួនដល់ក្រុមគ្រូពេទ្យ នៅឃុំដងក្ដារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវបេតុង និងផ្លូវក្រាលកៅស៊ូ DBST ចំនួន៤២ខ្សែ ប្រវែង៣១.៩១៧ម៉ែត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅក្រុងកំពង់ចាម ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២។

-នាំយកថវិកាមួយចំនួនចូលរួមទិវាកាកបាតក្រហម នៅសាខាកាកបាទក្រហមខេត្តត្បូងឃ្មុំ និងសាខាកាកបាទក្រហមខេត្តកំពង់ចាម នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។

-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ឯកឧត្តម **ហ៊ុន ណេង** ចំនួន៥៣នាក់ ទៅព្យាបាលជំងឺប្រជាពលរដ្ឋដោយឥតគិតថ្លៃចំនួន២០៩នាក់ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនដល់ក្រុមគ្រូពេទ្យនៅឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២។

❃ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងកម្មវិធីសម្ពោធផ្លូវ DBSTចំនួន៥ខ្សែ ប្រវែង ២.៧៩៧ គីឡូម៉ែត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅស្រុកស្ទឹងត្រង់ ឃុំសូភាស ឃុំដងក្ដា ឃុំអូរម្លូ ឃុំព្រែកកក់ និងឃុំអារក្សត្នោត ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២។

❃ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងពិធីសំណេះសំណាល និងសួរសុខទុក្ខគណៈចលនាសាសនិកខ្មែរឥស្លាមខេត្តកំពតចំនួន១១៥នាក់ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន និងសារុងចំនួន១ នៅភូមិកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមពិធីសំណេះសំណាលជាមួយនឹងគណៈចលនាសាសនិកខ្មែរឥស្លាមខេត្តកំពតចំនួន៧០នាក់ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅមន្ទីរពេទ្យបង្អែក ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២។



❃នាថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋចំនួន៥៦នាក់ នៅភូមិអូរគោល ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប។

❃នាថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **មួង ប៉ុយ** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ នៅភូមិកិត្តូង ឃុំវាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរី។

❃នាព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២២ លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពី ច្បាប់បទបញ្ញានីតិវិធី នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ

ទី៥ ឆ្នាំ២០២២ នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

❈នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនឹងគ្រូបង្រៀនចំនួន ១៥៦៥នាក់ និងសិល្បករ សិល្បការិនីចំនួន២៧នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង។

❈ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីសំណេះសំណាលជាមួយនឹងយុវជនភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុង ក្រោមអធិបតីភាព ឯកឧត្តម **គន់ គីម** ទេសរដ្ឋមន្ត្រី ដើម្បីស្តាប់របាយការណ៍សកម្មភាពក្រុមយុវជនលើការងារជួយរៀបចំដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ នាថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែមេសា និងថ្ងៃទី២៣-២៤ ខែឧសភា ឆ្នាំ២០២២។



-ចូលរួមគោរពវិញ្ញាណក្ខន្ធសព លោក **សេង ស៊ីន** សមាជិកក្រុមប្រឹក្សាស្រុកត្រពាំងប្រាសាទ នៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នារសៀលថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។

-ដឹកនាំកិច្ចប្រជុំជាមួយនឹងគណៈអភិបាលស្រុក និងប្រធានឃុំទាំង៦ ក្នុងស្រុកត្រពាំងប្រសាទ ដើម្បីស្តាប់របាយការណ៍ស្តីពីវឌ្ឍនភាពការងាររបស់អាជ្ញាធរស្រុក ស្ថិតនៅសាលប្រជុំសាលាស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។



-ចូលរួមពិធីបុណ្យផ្កាប្រាក់សាមគ្គី និងឆ្លងសមិទ្ធផលនានា ក្នុងវត្តឥន្ទរង្សីពោធិញាណ ព្រមទាំងបានចូលរួមជាសម្ភារ និងបច្ច័យមួយចំនួន នៅភូមិនគរភាស២ ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២។

❈ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមជាមួយនឹងក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ យុវជន និងប្រជាការពារភូមិទាំង៥ ក្នុងស្រុកជលគិរី ដើម្បីនាំយកសម្ភារ និងថវិការបស់សម្តេចចៅហ្វាវាំងវររៀងជ័យអធិបតីស្រីង្គារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ជូនប្រជាពលរដ្ឋឃុំកំពង់អុស ចំនួន៩២៣ គ្រួសារ នៅឃុំកំពង់អុសស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។



-ដឹកនាំកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំព្រៃគ្រីភូមិទាំង៥ និងប្រជាពលរដ្ឋចំនួន២៨៣នាក់ ដើម្បីស្តាប់សភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខ សណ្តាប់ធ្នាប់ការផ្តល់សេវាសាធារណៈ និងផែនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅសាលប្រជុំសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងលោកគ្រូ អ្នកគ្រូ ចំនួន៨៧ នាក់ ព្រមទាំងឧបត្ថម្ភសារុង អាវ មួក និងថវិកាមួយចំនួន នៅវិទ្យាល័យ ព្រះនរោត្តម សីហមុនី ឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមពិធីសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ចំនួន ៦៥៥នាក់ ឃុំទាំង៥ នៅសលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមពិធីសំណេះសំណាល និងផ្តល់អនុសាសន៍ដល់ក្រុមការងារថ្នាក់ស្រុក ក្រុមប្រឹក្សាស្រុក ឃុំ ចំនួន២៣២នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចចៅហ្វាវាំងវររៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ព្រមទាំងបានឧបត្ថម្ភសារុង និងថវិកាមួយចំនួន នៅសាលាស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមពិធីសំណេះសំណាលជាមួយនឹងអាជ្ញាធរ និងប្រជាពលរដ្ឋ នៅឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២។

※ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចុះសួរសុខទុក្ខប្រជាពលរដ្ឋ លោកតា លោកយាយ ចាស់ជរា ដែលមានជំងឺនៅភូមិស្ពានជ្រៃ ភូមិសំរោង ភូមិស្មាកកណ្តាល និងភូមិសុវណ្ណមាលា ព្រមទាំងចូលរួមក្នុងពិធីប្រគល់ផ្ទះ១ខ្នង ជូនជនពិការ និងចែកអំណោយដល់ជនពិការ១៨គ្រួសារ នៅភូមិអង្គរលើ ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី២៤ ថ្ងៃទី២៨ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។

-ចុះសួរសុខទុក្ខប្រជាពលរដ្ឋ លោកតា លោកយាយ និងចាស់ជរា ដែលមានជំងឺចំនួន១៤ភូមិ នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី១ ដល់ថ្ងៃទី២ និងថ្ងៃទី៦ ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមប្រជុំពិភាក្សាការងារជាមួយនឹងលោកប្រធានក្រុមប្រឹក្សា និងថ្នាក់ដឹកនាំភូមិ នៅសាលាឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងលោកគ្រូ អ្នកគ្រូ នគរបាល និងទាហាន ព្រមទាំងចូលរួមក្នុងពិធីសម្ពោធខ្លោងទ្វារ ទាំងប្រាំបី និងរបងវត្តបុទុមព្រឹក្ស(ហៅវត្តពពេលក្រោម) នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២។

※ឯកឧត្តម **ឆេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីសម្ពោធសាលាធម្មសភា និងសមិទ្ធផលនានា





ក្នុងវត្តថែង នៅភូមិពន្លៃ ឃុំធ្លក ស្រុកទ្រាំង ខេត្តតាកែវ នាព្រឹកថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២។

-ចូលរួមជាគណៈអធិបតីភាពក្នុងពិធីសម្ពោធផ្លូវបេតុងអំពេង សន្តិភាព ប្រវែង២.៧០០ម៉ែត្រ និងសំណង់សិល្បការមួយចំនួន នៅភូមិអំពេង ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។

※នាថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន១៥៣៥នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសណ្ឋាគារសុខា ខេត្តសៀមរាប។

※នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ គណៈកម្មការអាចារ្យវត្តចំនួន៨៦នាក់ នៅក្នុងឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប។

※នាព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសំណេះសំណាល និងចែកអំណោយដល់គ្រួសារក្រីក្រ ស្ត្រីមេម៉ាយ និងជនចាស់ជរាងាយរងគ្រោះចំនួន១០០គ្រួសារ រួមមាន៖ អង្ករ ត្រីខ ទឹកស៊ីអ៊ីវ និងថវិកាមួយចំនួននៅភូមិតាពេញ ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ

❋នាថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០២២ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពអ្នកម្នាង **ឌួង ឌីយ៉ាត** នៅវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

❋នាថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអនុញ្ញាតឱ្យក្រុមការងាររាជបណ្ឌិត្យសភាកម្ពុជា ដឹកនាំដោយឯកឧត្តមបណ្ឌិត **យង់ ពៅ** អគ្គលេខាធិការ ចូលជួបសម្ដែងការគួរសម និងសម្ភាសន៍ ដើម្បីរៀបចំធ្វើគុណកថាជូនឯកឧត្តមប្រធាន ក្នុងឱកាសដែលទទួលបានគោរមងារកិត្តិយស នៃរាជបណ្ឌិត្យសភាកម្ពុជា ជា «កិត្តិសេដ្ឋាបណ្ឌិត» នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងពិធីសម្ពោធបណ្ណាល័យអេឡិចត្រូនិក Kumnit App ជំនាន់ទី២ នៅសណ្ឋាគារសូហ្វីតែល រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលថ្លែងអំណរគុណ និងពិសាអាហារសាមគ្គីជាមួយនឹងក្រុមគ្រូពេទ្យសម្ដេចតេជោប្រឆាំងជំងឺកូវីដ-១៩ ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅដីព្រៃមៀសេនជ័រ សែនសុខ នារសៀលថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមពិធីបុណ្យសពឯកឧត្តម **ឫទ្ធី សំណាង** សមាជិកគណៈកម្មាធិការប្រតិបត្តិសហព័ន្ធកីឡាបាល់ទាត់កម្ពុជា និងជាប្រធានក្លិបបាល់ទាត់ភ្នំពេញក្រោន នៅគេហដ្ឋានលេខ១១ ផ្លូវលេខ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២។

-ទទួលជួបជាមួយនឹងថ្នាក់ដឹកនាំគណៈប្រតិភូមកពីប្រទេសចិន អញ្ជើញចុះទៅទស្សនកិច្ចសិក្សាឈ្វេងយល់នៅតំបន់អភិវឌ្ឍន៍កសិកម្ម កសិ-ឧស្សាហកម្មកែវផុស ចម្ការដូងប្រេង ចម្ការកៅស៊ូ ចម្ការឈើហូបផ្លែ រោងចក្រផលិតចំណីសត្វ កសិដ្ឋានចិញ្ចឹមជ្រូក រោងចក្រកែច្នៃស្បែក និងរោងចក្រស្លដែក នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។

❋នាថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២ លោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអនុញ្ញាតឱ្យក្រុមការងាររាជបណ្ឌិត្យសភា ចូលជួបសម្ដែងការគួរសម និងសម្ភាសន៍ ដើម្បីរៀបចំធ្វើគុណកថាជូនលោកជំទាវ ក្នុងឱកាសដែលទទួលបានគោរមងារកិត្តិយស នៃរាជបណ្ឌិត្យសភាកម្ពុជា នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា។



❋នាថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២២ លោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា និងលោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញទទួលបដិសណ្ឋារកិច្ច គណៈប្រតិភូក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា ដែលអញ្ជើញមកទស្សនាប្រាសាទសំបូរព្រៃគុក នៅខេត្តកំពង់ធំ។

❋ក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជាជាមួយសភានៃសាធារណរដ្ឋបារាំង ដឹកនាំដោយឯកឧត្តម **ម៉ុម ជីមហ៊ុយ** ប្រធានក្រុម និងជាប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ពិសាអាហារពេលល្ងាចជាមួយនឹងគណៈប្រតិភូក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា នៅលើទូកទេសចរណ៍តាមដងទន្លេចតុមុខ រាជធានីភ្នំពេញ នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២។



-ពិសាអាហារពេលល្ងាចជាមួយនឹងក្រុមមិត្តភាពព្រឹទ្ធសភា

បារាំង-កម្ពុជា នៅភោជនីយដ្ឋានTopaz នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីពិសាអាហារសាមគ្គីជាមួយនឹងឯកឧត្ដម Vincent Eblé ប្រធានក្រុមមិត្ដភាពព្រឹទ្ធសភាបារាំង-កម្ពុជា នៅស្ថានទូតបារាំង រាជធានីភ្នំពេញ នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។



✻នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ឯកឧត្ដម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពលោកឧកញ៉ា **ឫទ្ធី សំណាង** នៅផ្ទះលេខ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។



✻ឯកឧត្ដម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្ដម **ឆាយ ថណ្ណា** លេខាធិការគណៈ-កម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាស្ដីពី “ពាណិជ្ជកម្មអន្ដរជាតិ ២០២២” តាមប្រព័ន្ធនិម្មិត (Zoom) នៅសាលប្រជុំពិសេសព្រឹទ្ធសភា នាថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២។

✻ឯកឧត្ដម **ឈិត គីមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមទស្សនាការដាក់តាំងពិព័រណ៍រូបថត ដើម្បីរំលឹកខួបរយៈពេល៣០ឆ្នាំ នៃរបបប្រល័យពូជសាសន៍ប៉ុលពត នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ភ្នំពេញ នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២។

-ចូលរួមកិច្ចប្រជុំសភាតំបន់អាស៊ី (APA) ក្រោមប្រធានបទ “វេទិកាសភាស្ដីពីការស្រាវជ្រាវ និងសហប្រតិបត្តិការកិច្ចការបណ្ណាល័យ” នៅរដ្ឋសភា តាមប្រព័ន្ធនិម្មិត ដែលផ្សាយចេញពី




ប្រទេសអ៊ីរ៉ង់ នារសៀលថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២។

-ចូលរួមទទួលគណៈប្រតិភូរដ្ឋសភា នៃសាធារណរដ្ឋឥណ្ឌា នៅអាកាសយានដ្ឋានអន្ដរជាតិភ្នំពេញ នាថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២។

-ចូលរួមជាកិត្ដិយសក្នុងពិធីលៀងសាយភោជន៍ជូនគណៈ-ប្រតិភូរដ្ឋសភា នៃសាធារណរដ្ឋឥណ្ឌា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២។

-ចូលរួមជូនដំណើរនិវត្ដន៍របស់គណៈប្រតិភូរដ្ឋសភា នៃសាធារណរដ្ឋឥណ្ឌា នៅអាកាសយានដ្ឋានអន្ដរជាតិភ្នំពេញ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២។

✻ឯកឧត្ដម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិសាអាហារស្រាយបួសរ៉ាម៉ាឌន នៅទូតគុយវ៉ែតប្រចាំនៅកម្ពុជា នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២២។



-ចូលរួមពិសាអាហារស្រាយបួសរ៉ាម៉ាឌន នៅស្ថានទូតប៉ាគីស្ថានប្រចាំនៅកម្ពុជា នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២។



-ចូលរួមប្រជុំពិភាក្សាការងារ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំប្រចាំឆ្នាំលើកទី៥ នៃក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ា ស្ដីពីគ្រឿងញៀន ក្រោមអធិបតីភាពឯកឧត្ដម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការទី៥រដ្ឋសភា នៅសាលប្រជុំបន្ទាយស្រីរដ្ឋសភា នាព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២។



※នាថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២ ឯកឧត្ដម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្ដម **សាយ ប៊ូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំត្រៀមរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ AIPACODD លើកទី៥ក្រោមអធិបតីភាពឯកឧត្ដមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា និងជាប្រធានគណៈកម្មការរៀបចំសម្រាប់កិច្ចប្រជុំប្រចាំឆ្នាំ AIPACODD លើកទី៥ នៅសាលប្រជុំបាយ័នរដ្ឋសភា។

※នាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ ឯកឧត្ដម **ម្លូច ម៉ៃ** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីជំនួបប្រាស្រ័យមិត្តភាពការពារជាតិព្រំដែនកម្ពុជា-វៀតណាម ថ្នាក់រដ្ឋមន្ត្រីការពារជាតិលើកទី១ ដឹកនាំដោយសម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសាលាបឋមសិក្សាហ៊ុន សែន ២ធ្នូ នៅភូមិចុងគ្លួ ស្រុកស្នួល ខេត្តក្រចេះ។



※នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ លោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹត្តសភា លោកជំទាវ **ឃួន យុនឌី** លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី ថណ្ណាថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងវេទិកាជាតិស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២រដ្ឋសភា និងជាប្រធានក្រុមសភាជាតិកម្ពុជា នៃអ្នកនយោបាយស្ត្រី នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ រាជធានីភ្នំពេញ។

※លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកចង្ហាន់ ទ័យវត្ថុ និងបច្ច័យមួយចំនួនទៅប្រគេនព្រះសង្ឃគង់នៅវត្តសំប្ួរមាស ស្ថិតនៅក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២២។

-នាំយកចង្ហាន់ ទ័យវត្ថុ និងបច្ច័យមួយចំនួនទៅប្រគេនព្រះសង្ឃគង់នៅវត្តទួលទំពូង ស្ថិតនៅក្នុងសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២។



-ដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធឯកឧត្ដម Alarcónde Quesada អតីតប្រធានរដ្ឋសភា និងរដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋគុយបា នៅស្ថានទូតគុយបាប្រចាំព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅសង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២។



-ចូលរួមអមដំណើរគណៈប្រតិភូព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **អ៊ុំ សូម៉ានីន** តំណាងឱ្យព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធអ្នកម្នាង **ឌួង ឌីយ៉ាត** ដែលបានទទួលមរណភាព កាលថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ ក្នុងជន្មាយុ៧៤ឆ្នាំ ដោយរោគាពាធ នៅវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២៕

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិនិត្យ ពិភាក្សា និងផ្ដល់យោបល់លើសេចក្ដីព្រាងស្ដីពី ទម្រង់ទិន្នន័យសមាជិកព្រឹទ្ធសភា នីតិកាលនីមួយៗ និងការទទួលពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋមកកាន់ព្រឹទ្ធសភាតាមប្រព័ន្ធឌីជីថល នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យលោក Antoine RIPOLL អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយអន្តរជាតិ និងទំនាក់ទំនងជាមួយនឹងអាស៊ាន អាស៊ីអាគ្នេយ៍នៃសភាអាស៊ី ដើម្បីបង្កើនទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ និងជួយបណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាពសិក្ខាកាម នៃកម្មវិធីការទូតសភា នៅសាលប្រជុំពិសេស១ វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជូនដំណើរគណៈប្រតិភូក្រុមមិត្តភាពព្រឹទ្ធសភាបារាំង-កម្ពុជា ធ្វើមាតុភូមិនិវត្តន៍ត្រឡប់ទៅកាន់ប្រទេសបារាំង នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។



❈នាព្រឹកថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គ បណ្ដុះបណ្ដាលភាសាអង់គ្លេស សម្រាប់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាខាងជើង វិមានព្រឹទ្ធសភា។




❈នារសៀលថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២១ របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២២ និងរបាយការណ៍អនុវត្តសូចនាករសមិទ្ធកម្មគន្លឹះប្រចាំត្រីមាសទី១ ឆ្នាំ២០២២ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំស្ដីពី ផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ របស់ព្រឹទ្ធសភា និងគម្រោងថវិកាឆ្នាំ២០២៣ របស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាលការងារជាមួយនឹងសន្តិសុខផ្ទៃក្នុង នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងត្បូង វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី១ និងលើកទិសដៅការងារបន្ត ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តម **ប៊ុន ឧទ្ធា** អគ្គនាយក នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **ទេព ចាន់អុនឧធីរក្ស** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានអញ្ជើញទៅទស្សនកិច្ចសិក្សានៅក្រុមហ៊ុន Huawei រាជធានីភ្នំពេញ៕



